# របាយការណ៍
# ស្តីពី
# ស្ថានភាពកុមារកម្ពុជា ឆ្នាំ២០១៦ និងទិសដៅ ឆ្នាំ២០១៧

## I- សេចក្តីផ្តើម

១- រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឆ្នាំ២០០៥ អនុសញ្ញារអង្គការពលកម្មអន្តរជាតិលេខ១៣៨ ស្តីពីការកំណត់អាយុអប្បបរមាសម្រាប់ការចូលធ្វើការងារឆ្នាំ១៩៩៩ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសឆ្នាំ២០០៧ ពិធីសារបន្ថែមនៃអនុសញ្ញាប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែល មានអង្គការចាត់តាំងស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០៦ អនុសញ្ញាស្តីពីសិទ្ធិជនពិការឆ្នាំ២០១២។ល។ ដើម្បីការការពារ និងជាឧត្តមប្រយោជន៍កុមារ។

២- ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ការលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់អន្តរជាតិពាក់ព័ន្ធ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ និងការប្តេជ្ញាចិត្តគោរព ការពារ និងបំពេញសិទ្ធិនានាចំពោះប្រជាពលរដ្ឋ ជាពិសេសកុមារ ដើម្បីរស់នៅក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ សមភាព និងសុវត្ថិភាព ស្របតាមរដ្ឋធម្មនុញ្ញ និងគោលការណ៍នីតិរដ្ឋ ដែលបានដាក់ចេញនូវវិធានការជាច្រើន រួមមាន ការអនុម័តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋាន យន្តការ កិច្ចសហការថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីធានាឲ្យបាននូវសុខុមាលភាព និងការគាំពារសង្គមចំពោះកុមារកម្ពុជា។

៣- ផ្អែកតាមការអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាច្រើន រួមមាន ការរក្សាបាននូវសន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងសម្រេចបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧% ផ.ស.ស សម្រាប់មនុស្សម្នាក់ៗបន្តកើនដល់១.៣០០ដុល្លារអាមេរិក ដែលធ្វើឲ្យកម្ពុជាបានឆ្លងផុតពីចំណាត់ថ្នាក់ជាប្រទេសចំណូលទាប ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។[១] អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយមកត្រឹម១៤% ក្នុងឆ្នាំ២០១៤[២] ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា និងការបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់។[៣]

---

[១] ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៦ ផ្អែកលើទិន្នន័យ៦ខែ ដើមឆ្នាំ។

[២] របាយការណ៍ស្តីពីការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣-២០១៥។

[៣] ការវាយតម្លៃកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៦ ផ្អែកលើទិន្នន័យ៦ខែ ដើមឆ្នាំ។

៤- ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន១៤.៦៧៦.៥៩១នាក់ ជាមួយនឹងកំណើនប្រចាំឆ្នាំ១,៨៣% ក្នុងនោះស្ត្រី៧.៥៥៥.០៨៣នាក់ ស្មើនឹង៥១,៤៧%។ កុមារអាយុក្រោម១៨ឆ្នាំមានចំនួន៥.២១៧.៧៣៣នាក់ ស្មើ៣៥,៥% នៃចំនួនប្រជាជនសរុប និងកុមារពីអាយុ០-៦ឆ្នាំ មានចំនួន១.៩២២.៩៦៩នាក់ ស្មើនឹង១៣,១% នៃចំនួនកុមារសរុប។[៤]

## II- សមិទ្ធផលសំខាន់ៗសម្រេចបាន និងការឆ្លើយតបអនុសាសន៍រាជរដ្ឋាភិបាល ក្នុងឆ្នាំ២០១៦

៥- ឆ្លើយតបទៅនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងឱកាសខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៦ ក៏ដូចជាការឆ្លើយតបនឹងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (ឆ្នាំ២០១៦-២០១៨) ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិនានា ប្រជាជន សហគមន៍ ព្រះសង្ឃ ព្រឹទ្ធាចារ្យ មាតាបិតា និងកុមារខ្លួនឯងផ្ទាល់ ដែលបានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជា បានសម្រេចនូវសមិទ្ធផលសំខាន់ៗជាច្រើន រួមមានដូចខាងក្រោម ៖

### ក. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

**អនុសាសន៍ទី១ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*ជំរុញការអនុវត្តផែនការជាតិអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ ដើម្បីរួមចំណែកក្នុងការសម្រេចបានចំណុចដៅរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។*

**អនុសាសន៍ទី៨ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៦៖**

*ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវដាក់បញ្ចូលបញ្ហាកុមារទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីតាមដានការអនុវត្តសិទ្ធិកុមារ និងផ្តល់អនុសាសន៍នានាក្នុងការចាត់វិធានការដោះស្រាយបញ្ហាកុមារ និងធានាជួយដល់កុមារឲ្យរួចផុតពីការរលោភបំពាន ការកេងប្រវ័ញ្ច និងការរើសអើងគ្រប់រូបភាពឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី៤៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

៦- រាជរដ្ឋាភិបាល បានអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦។ ច្បាប់នេះ បានធ្វើការផ្សព្វផ្សាយបានចំនួន០៤ដង គឺនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួង ស.អ.យ ដែលមានសមាសភាពចូលរួមចំនួន៣២៩នាក់ (ស្រី២១៧នាក់) មកពីមន្ទីរ ស.អ.យ រាជធានី ខេត្តទាំង២៥ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីស្តីការក្រសួង ស.អ.យ

[៤] អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជា ឆ្នាំ២០១៣។

ក្រោមអធិបតីភាពឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួង ស.អ.យ ដែលមានសមាសភាពចូលរួមចំនួន១៦៩នាក់ (ស្រី៥៧នាក់) មកពីមន្ទីរ ស.អ.យ រាជធានី ខេត្តទាំង២៥ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ នៅខេត្តស្វាយរៀង ដែលមានសមាសភាពចូលរួមចំនួន៥៩នាក់ (ស្រី១៨នាក់) និងនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ នៅខេត្តក្រចេះ ដែលមានសមាសភាពចូលរួមចំនួន៥៤នាក់ (ស្រី១៥នាក់)។

ជាមួយគ្នានេះដែរ យោងតាមជំពូកទី១៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្រសួង ស.អ.យ បានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលមានសមាសភាពដឹកនាំដោយរដ្ឋលេខា០១រូបមកពីក្រសួង ស.អ.យ អនុប្រធាន០២រូបមកពីក្រសួងយុត្តិធម៌ និងអគ្គលេខាធិការដ្ឋាន ក.ជ.ក ព្រមទាំងមានសមាជិកមកពីក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ។ ជាលទ្ធផល ក្រុមការងារបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ក្នុងគោលបំណងកំណត់អំពីការបង្កើតមណ្ឌលយុវនីតិសម្បទា ដោយបានប្រជុំពិភាក្សាជាច្រើនលើក។ បច្ចុប្បន្ន សេចក្តីព្រាងអនុក្រឹត្យនេះ បានរៀបចំដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី។

៧- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) បាននិងកំពុងជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (២០១៦-២០១៨) តាមរយៈការផ្សព្វផ្សាយ និងបញ្ជ្រាបផែនការជាតិនេះទៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ខេត្ត។ ជាក់ស្តែង អគ្គលេខាធិការដ្ឋាន ក.ជ.ក. បានបញ្ជ្រាបផែនការនេះដល់ក្រសួងចំនួន ៣ រួមមាន ក្រសួង ស.អ.យ សុខាភិបាល និងក្រសួងកិច្ចការនារី។ ទន្ទឹមនឹងនេះដែរ អគ្គលេខាធិការដ្ឋាន ក.ជ.ក. បានបញ្ជ្រាបផែនការជាតិនេះដល់ខេត្តចំនួន ៣ គឺ ខេត្តត្បូងឃ្មុំ សៀមរាប និងខេត្តព្រៃវែង។ ជាលទ្ធផល ផែនការសកម្មភាពនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការប្រតិបត្តិរបស់ ក.ជ.ក. ខេត្ត។

៨- ក្រសួងកិច្ចការនារី បានបញ្ចូលផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារទៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ ដើម្បីរួមចំណែកជំរុញការលើកកម្ពស់សិទ្ធិកុមារ និងលុបបំបាត់ការរើសអើងចំពោះកុមារ និងអនុវត្តសកម្មភាពសំខាន់ៗ ក្នុងការការពារ និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារនៅកម្ពុជា។ ក្រសួងបានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនានា និងបានពង្រឹងការងារកិច្ចការពារកុមារតាមរយៈយន្តការខ្សែបណ្តោយ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធអំពីបញ្ហាកុមារ ព្រមទាំងបានលើកកម្ពស់សិទ្ធិចូលរួមរបស់កុមារតាមរយៈការធ្វើវេទិកាកុមារ ការផ្សព្វផ្សាយ និងការអនុវត្តគោលការណ៍ចូលរួមរបស់កុមារ។[៥]

៩- ក្រសួងសាធារណការ និងដឹកជញ្ជូន បានរៀបចំវិសោធនកម្មនៃច្បាប់ស្តីពីចរាចរណ៍ ក្នុងគោលបំណងបង្ការទប់ស្កាត់បទល្មើស និងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក រក្សាសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោក និងការពារអាយុជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ជាពិសេសកុមារ ព្រមទាំងបានធ្វើការផ្សព្វផ្សាយនៅតាមបណ្តារាជធានី ខេត្ត និងតាមប្រព័ន្ធអ៊ិនធឺណិត ដើម្បីឱ្យប្រជាជនបានយល់ដឹងពីអត្ថប្រយោជន៍សម្រាប់សុវត្ថិភាពខ្លួនឯងផង និងសុខសន្តិភាពក្នុងសង្គមផងដែរ រួមទាំងផលប៉ះពាល់យ៉ាងខ្លាំងនៅពេលមានគ្រោះថ្នាក់កើតឡើង។

---

[៥] ប្រភព៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

១០- រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ តាមព្រះរាជក្រឹត្យលេខនស/រកត/១១១៦/១០៩៩ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦។ គណៈកម្មការនេះ មានសមាសភាពដឹកនាំដោយប្រធាន០១រូបមកពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអនុប្រធាន០៥រូប ព្រមទាំងសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ គណៈកម្មាធិការជាតិមានតួនាទីជំរុញការអនុវត្តគោលនយោបាយ ផែនការសកម្មភាពជាតិ បទដ្ឋាន ច្បាប់ បទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញានៃអង្គការពលកម្មកុមារ និងសហការជាមួយ ក.ជ.ក អនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ គណៈកម្មាធិការជាតិនេះ នឹងមានរចនាសម្ព័ន្ធនៅថ្នាក់រាជធានី ខេត្ត។

ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលបានអនុតម័តផែនការជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ២០១៦-២០២៥ កាលពីថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលផែនការជាតិនេះបានកំណត់វិស័យ និងចំនួនកុមារ ដែលត្រូវលុបបំបាត់តាមគោលដៅកំណត់។

១១- រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ៨៤ ស.ស.រ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ស្តីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ដែលមានសមាសភាពដឹកនាំដោយប្រធាន០១រូបមកពីក្រសួងកិច្ចការនារី និងអនុប្រធាន០៤រូបមកពីក្រសួងទេសចរណ៍ ស.អ.យ មហាផ្ទៃ និងក្រសួងកិច្ចការនារី ព្រមទាំងសមាជិកមកពីក្រសួងពាក់ព័ន្ធជាច្រើនទៀត។ ក្រុមការងារមានតួនាទី និងភារកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រុមការងារតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងក្រោមជាតិពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សហការជាមួយប្រទេសជាសមាជិកខមមីតនៅក្នុងមហាអនុតំបន់មេគង្គ និងក្នុងតំបន់ឱ្យបានសកម្ម និងមានប្រសិទ្ធភាព។ ដោយមានកិច្ចសហការជាមួយគម្រោងសកម្មភាពអង្គការសហប្រជាជាតិ ដើម្បីធ្វើសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស ហៅកាត់ថា UN-ACT ប្រចាំកម្ពុជាថ្នាក់តំបន់ប្រចាំទីក្រុងបាងកក និងអង្គការជាតិ អន្តរជាតិ រួមជាមួយបណ្តាដៃគូអភិវឌ្ឍន៍ដទៃទៀត ក្រុមការងារបានរៀបចំផែនការសកម្មភាពខមមីតកម្ពុជា និងផែនការថ្នាក់មហាអនុតំបន់មេគង្គ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) បានចេញប្រកាសលេខ៤៨២ ស.អ.យ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកែប្រែមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈពោធិ៍សែនជ័យទៅជាមជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅភូមិស្រែជម្រៅ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ ស.អ.យ។ មជ្ឈមណ្ឌល ផ្តល់សេវាស្នាក់នៅបណ្តោះអាសន្នប្រកបដោយសុវត្ថិភាព និងទទួលបានសេវាហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ធ្វើការបញ្ជូនបន្តទៅដៃគូអភិវឌ្ឍន៍ និងសមាហរណកម្មទៅសហគមន៍វិញ។ មណ្ឌលជួយសង្គ្រោះដល់ជនរងគ្រោះ និងជនងាយរងគ្រោះជាកុមារ ដោយគ្មានការរើសអើងជាតិសាសន៍ ពណ៌សម្បុរឡើយ។

១៣- ក្រសួង ស.អ.យ បានចេញសេចក្តីសម្រេចលេខ៨៦៣ស.អ.យ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលក្រុមការងារបច្ចេកទេស ដើម្បីជួយគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ដែលមានសមាសភាពដឹកនាំដោយប្រធាន០១រូបមកពីក្រសួង ស.អ.យ អនុប្រធាន០៤រូបមកពីក្រសួងព័ត៌មាន ស.អ.យ យុត្តិធម៌ និងក្រសួងទេសចរណ៍ ព្រមទាំងសមាជិកមកពីក្រសួង

ពាក់ព័ន្ធ និងអង្គការដៃគូពាក់ព័ន្ធ។ ក្រុមការងារមានភារកិច្ចស្រាវជ្រាវ និងលើកដំណោះស្រាយបញ្ហាជូនគណៈកម្មាធិការជាតិដោះស្រាយជនអនាថា រៀបចំផែនការយុទ្ធសាស្ត្រជាតិ ផ្តល់បច្ចេកទេស និងកិច្ចសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូរ ក្នុងការផ្តល់សេវាដល់ជនអនាថា។

១៤- ក្រសួង ស.អ.យ បានចេញប្រកាសលេខ ៣០៨ ស.អ.យ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតបង្កើតមណ្ឌលថែទាំកុមារ ដែលសំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងបង្កើតមណ្ឌលថែទាំកុមារ ត្រូវមានការអនុញ្ញាតពីក្រសួង ស.អ.យ និងត្រូវបំពេញ គោរព និងអនុវត្តនូវលក្ខខណ្ឌនៃការបង្កើតមណ្ឌលថែទាំកុមារ ដែលមានចែងក្នុងជំពូកទី២ នៃប្រកាសលេខ៦១៦ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល។

១៥- ក្រសួង ស.អ.យ បានចេញប្រកាសលេខ១៧៤៩ ស.អ.យ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត។ មជ្ឈមណ្ឌលមានតួនាទី និងភារកិច្ចផ្តល់សេវាស្នាក់នៅបណ្តោះអាសន្នប្រកបដោយសុវត្ថិភាព និងគ្មានការរើសអើងជាតិសាសន៍ វណ្ណៈ ពិការភាព ភេទ ជួយសង្គ្រោះដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទទួលបានការស្នាក់នៅបណ្តោះអាសន្ន ហូបចុក ថែទាំសុខភាព ព្យាបាលជំងឺ អប់រំ បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បំណិនជីវិត ធ្វើការបញ្ជូនបន្តទៅដៃគូអភិវឌ្ឍន៍ និងសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញ។ មជ្ឈមណ្ឌលត្រូវដឹកនាំដោយប្រធាន១រូប ដែលមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន និងមានអនុប្រធាន២រូបជាជំនួយការមានឋានៈស្មើនឹងប្រធានការិយាល័យថ្នាក់កណ្តាល។

១៦- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀនស្របតាមមាត្រា៩៧នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២។ អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិខាងលើនេះឲ្យមាននិរន្តរភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សកម្មភាពសម្ងាត់ និងបន្ទាន់ សំដៅរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនប្រកបដោយប្រសិទ្ធភាព។

១៧- ឆ្លើយតបនឹងអនុក្រឹត្យលេខ១៩១អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងមណ្ឌល កម្សាន្តទេសចរណ៍មនុស្សពេញវ័យ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍ មនុស្សពេញវ័យឲ្យទទួលបាននូវប្រសិទ្ធភាព និងធានាបាននូវគុណភាពសេវាកម្មទេសចរណ៍ និងចូលរួមទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានក្នុងវិស័យទេសចរណ៍ រក្សាបាននូវសណ្តាប់ធ្នាប់ សុវត្ថិភាព ព្រមទាំងធានាដល់ការថែរក្សាបរិស្ថាន វប្បធម៌ ប្រពៃណី និងសេចក្តីថ្លៃថ្នូរបស់ជាតិ ក្រសួងទេសចរណ៍បានចេញប្រកាសលេខ០៦៩ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មមុខងារ "ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ" ទៅឲ្យរដ្ឋបាល

រាជធានីខេត្ត និងបានចេញ សេចក្តីណែនាំលេខ០០៥សណន ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ ស្តីពីការអនុវត្តប្រកាស០៦៩។ ដោយឡែក ក្រសួងក៏បានចេញសេចក្តីសម្រេចលេខ៣៧៦៨ស.ស.រ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងការចាត់ចែង និងការអនុវត្តមុខងារ ការគ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យនៅរាជធានី ខេត្ត។

**១៨**-ក.ជ.ក. បានសហការជាមួយក្រសួង ស.អ.យ រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីកិច្ចការពារកុមារ និងក្រមសីលធម៌ការពារកុមារ ក្នុងគោលបំណង៖ ១)-ការពារសិទ្ធិ និងសុខុមាលភាពកុមារ ការពារសិទ្ធិកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកធ្វើការងារពាក់ព័ន្ធជាមួយកុមារ និងអង្គភាពនីមួយៗ ក្នុងការកាត់បន្ថយហានិភ័យក្នុងពេលបំពេញការងារ។ ២)-កំណត់នូវបទដ្ឋានអប្បបរមា និងនីតិវិធីជាមូលដ្ឋានសម្រាប់អនុវត្តនៅតាមស្ថាប័ន ឬអង្គភាព និងកន្លែងផ្សេងៗទៀត ដែលមានទំនាក់ទំនងតាមគ្រប់មធ្យោបាយជាមួយកុមារដោយផ្ទាល់ ឬដោយប្រយោល។ ៣)-លុបបំបាត់ និងបង្ការគ្រោះថ្នាក់ និងហានិភ័យចំពោះកុមារដែលបណ្តាលមកពីការរំលោភបំពានលើកុមារ ការកេងប្រវ័ញ្ចកុមារ និងការមិនយកចិត្តទុកដាក់លើកុមារ។ ៤)-កំណត់អំពីវិធាននិងក្រមសីលធម៌ពិសេសដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់ និងបែបបទនៃការអនុវត្តក្នុងការប្រព្រឹត្តចំពោះកុមារ។ បទបញ្ញត្តិនៃច្បាប់ និងបទដ្ឋានក្រោមច្បាប់ ព្រមទាំងវិធានដោយឡែកផ្សេងទៀតត្រូវយកមកអនុវត្តលើកលែងតែក្នុងករណីដែលមានចែងនៅក្នុងអនុក្រឹត្យនេះ។ សេចក្តីព្រាងអនុក្រឹត្យនេះ នឹងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីនាពេលឆាប់ៗខាងមុខនេះ។

**១៩**-ក្រសួងផែនការ បានចូលរួមរៀបចំក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) ដែលទទួលការអនុម័តពីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។ ក្របខណ្ឌគោលនយោបាយនេះ គឺជាផែនទីបង្ហាញផ្លូវរយៈពេលវែងផ្តោតលើសសរស្តម្ភ ២ គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ ដោយឡែកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) បានកំណត់យកការបន្តពង្រឹង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព ជាគោលដៅអាទិភាព។

**២០**-ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានពិភាក្សា និងរៀបចំធ្វើសេចក្តីព្រាងសេចក្តីសម្រេចបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទប់ស្កាត់ ផ្សព្វផ្សាយ ចែកចាយរូបភាពអាសអាភាស និងព័ត៌មានអវិជ្ជមាន ដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការជំរុញកិច្ចការងារការពារ និងទប់ស្កាត់រាល់ការចែកចាយព័ត៌មានអវិជ្ជមាន ជាពិសេសអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមរយៈ ការចែកចាយវីដេអូ និងរូបភាពអាសអាភាស ដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលប៉ះពាល់ដល់កុមារ និងស្ត្រី។

## ខ. សិទ្ធិជាមូលដ្ឋានរបស់កុមារ

### ១-សិទ្ធិរស់រានមានជីវិត[៦]

អនុវត្តតាមអនុសាសន៍ទី១របស់រាជរដ្ឋាភិបាលខាងលើ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី២៖ លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ) សម្រេចបាន

---

[៦] សិទ្ធិនេះរួមបញ្ចូល សិទ្ធិមានជីវិត សិទ្ធិទទួលបានការថែទាំសុខភាព និងវេជ្ជសាស្ត្រក្នុងកម្រិតខ្ពស់បំផុត។

នូវលទ្ធផលដូចខាងក្រោម៖

២១- ក្រសួងសុខាភិបាលបានអនុវត្តការថែទាំសុខភាពកុមារ ដោយផ្សារភ្ជាប់ជាមួយនឹងការថែទាំសុខភាពស្ត្រីក្នុងពេលមានគភ៌ ពេលឈឺពោះសម្រាល ពេលសម្រាលកូន និងក្រោយពេលសម្រាលរួច ព្រមទាំងការចិញ្ចឹមបីបាច់ថែទាំសុខភាពទារកទើបនឹងកើត កុមារតូច រហូតដល់កុមារចម្រើនវ័យ។ ក្នុងន័យនេះ ក្រសួងសុខាភិបាលបានបង្កើនការគ្របដណ្តប់ និងលទ្ធភាពទទួលបានសេវាថែទាំគភ៌មុនសម្រាល សម្រាលមានសុវត្ថិភាព ថែទាំក្រោយសម្រាល សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកមានគុណភាព ព្រមទាំងសេវាបង្ការការចម្លងមេរោគពីម្តាយទៅកូន ការផ្តល់ថ្នាំបង្ការជំងឺ១១មុខ (របេង រលាកថ្លើមប្រភេទបេ ក្អកមាន់ ខាន់ស្លាក់ តេតាណូស គ្រុនស្វិតដៃជើង រលាកសួត រលាកស្រោមខួរក្បាល កញ្ជ្រឹល ស្អូច និងរលាកខួរក្បាលជេអ៊ី) ការបំបៅកូនដោយទឹកដោះម្តាយ ការតាមដានការលូតលាស់របស់កុមារ ការផ្តល់មីក្រូសារជាតិ-វីតាមីន-ថ្នាំទម្លាក់ព្រូន ការពិនិត្យព្យាបាលកុមារដែលមានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរស្រួចស្រាវ។ ជាលទ្ធផល៖


*រូបភាពដកស្រង់ពីPage Facebook សម្តេចតេជោនាយករដ្ឋមន្ត្រី*

- ការបំបៅកូននៅម៉ោងដំបូងក្រោយសម្រាល មានការកើនឡើងនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈពី៦២,៦% នៅឆ្នាំ២០១៥ ដល់៦៤,៦% នៅឆ្នាំ២០១៦។ ចំនួនកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរស្រួចស្រាវ ត្រូវបានធ្វើការស្រាវជ្រាវតាមរក និងបានមកទទួលការព្យាបាល មានការកើនឡើងពី២.៩៨៦នាក់ នៅឆ្នាំ២០១៥ ដល់៥.៧៧៥នាក់ នៅឆ្នាំ២០១៦ ធៀបទៅនឹងចំនួនព្យាករណ៍៦០០០នាក់។
- ការផ្តល់ថ្នាំបង្ការជំងឺចំនួន១១មុខទៅតាមកាលកំណត់ជាប្រចាំ ត្រូវបានអនុវត្ត រួមទាំងការផ្តល់បន្ថែមតាមរយៈការធ្វើយុទ្ធនាការនៅទូទាំងប្រទេស។ សូចនាករសំខាន់មួយបានបង្ហាញថា ការផ្តល់ថ្នាំបង្ការជំងឺតេតាណូស ខាន់ស្លាក់ ក្អកមាន់ រលាកសួត រលាកស្រោមខួរក្បាល រលាកថ្លើមប្រភេទបេពដូស មានការកើនឡើងពី៩៤,៣% នៅឆ្នាំ២០១៥ ដល់៩៦,៨% នៅឆ្នាំ២០១៦។
- ស្ត្រីក្នុងវ័យបន្តពូជដែលបានរៀបការ ហើយកំពុងប្រើមធ្យោបាយពន្យាកំណើតទំនើបនៅមូលដ្ឋានសុខាភិបាលសាធារណៈ មានចំនួន៧១៤.១៩១នាក់។
- ការពិនិត្យថែទាំមុនសម្រាល២លើកដោយបុគ្គលិកសុខាភិបាល មានការកើនឡើងពី៩៣.១% នៅឆ្នាំ២០១៥ ដល់៩៦.៦% នៅឆ្នាំ២០១៦។ ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលសាធារណៈ (មណ្ឌលសុខភាព និងមន្ទីរពេទ្យ) នៅឆ្នាំ២០១៦ មានចំនួន៨០% នៃស្ត្រីមានគភ៌រំពឹងទុក។ ស្ត្រីដែលទទួលបានការពិនិត្យក្រោយសម្រាល០២លើក ដោយបុគ្គលិកសុខាភិបាល មានការ

កើនឡើងពី៥២.៣% នៅឆ្នាំ២០១៥ ដល់៥៤.៣% នៅឆ្នាំ២០១៦។ ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈ ដែលអនុវត្តការបង្ការការចម្លងមេរោគពីមាតាទៅកូនមានចំនួន១.២៦៥កន្លែងនៅឆ្នាំ២០១៦។[៧]

| សូចនាករ | ២០១៥ | ២០១៦ |
|---|---|---|
| ការបំបៅកូននៅម៉ោងដំបូងក្រោយសម្រាលភ្លាមនៅមន្ទីរពេទ្យ និងមណ្ឌលសុខភាពសាធារណៈ | ៦២,៦% | ៦៤,៦% |
| ចំនួនកុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរស្រួចស្រាវទទួលបានការព្យាបាល | ២.៩៨៦ន. | ៥.៧៧៥ន. |
| %នៃការផ្តល់ថ្នាំបង្ការជំងឺតេតាណូស ខាន់ស្លាក់ ក្អកមាន់ រលាកសួត រលាកស្រោមខួរក្បាល រលាកថ្លើមប្រភេទបេ៣ដូស | ៩៤,៣ | ៩៦,៨ |
| ចំនួនស្ត្រីក្នុងវ័យបន្តពូជដែលរៀបការកំពុងប្រើមធ្យោបាយពន្យារកំណើតទំនើប | ៧១៥.៥៩៦ន. | ៧១៤.១៩១ន. |
| %នៃស្ត្រីមានគិតបានទទួលការថែទាំមុនសម្រាល២លើកដោយបុគ្គលិកសុខាភិបាល | ៩៣,១ | ៩៦,៦ |
| %នៃស្ត្រីសម្រាលកូននៅមន្ទីរពេទ្យ និងមណ្ឌលសុខភាពសាធារណៈ | ៨០,៣៥ | ៨០,៥២ |
| %នៃស្ត្រីទទួលបានការពិនិត្យក្រោយសម្រាល២លើកដោយបុគ្គលិកសុខាភិបាល | ៥២,៣ | ៥៤,៣ |
| ចំនួនមូលដ្ឋានសុខាភិបាលដែលអនុវត្តការបង្ការការចម្លងមេរោគពីម្តាយទៅកូន | ១.២១៦ | ១.២៦៥ |

**២២**-ក្រសួងផែនការមានកម្មវិធីជំនួយសង្គម ផ្តោតលើការផ្តល់ការគាំពារដល់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដែលបានបែងចែកជា៣ក្រុម ក្នុងនោះក៏រួមមានក្រុមទារក និងកុមារផងដែរ។ កុមារតូចៗនឹងត្រូវបានយកចិត្តទុកដាក់ជាពិសេស ព្រោះរយៈពេល១.០០០ថ្ងៃដំបូងនៃជីវិត គឺជារយៈពេលដ៏សំខាន់សម្រាប់ការរីកលូតលាស់។

**២៣**-កាកបាទក្រហមកម្ពុជា បានអនុវត្តសកម្មភាពស្តីពីសុខភាពមាតា ទារក និងកុមារ គ្រប់២៥រាជធានីខេត្ត។ មានគម្រោងអភិវឌ្ឍសុខភាពសហគមន៍មូលដ្ឋាន បានអនុវត្តនៅខេត្តព្រះវិហារ និងកំពត ក្នុង ០៥ ស្រុក ០៩ ឃុំ ៨៧ភូមិ អនុវត្តដោយអ្នកស្ម័គ្រចិត្ត៣២២នាក់ និងមានអ្នកទទួលផលសរុបចំនួន៨៦.៩៩០ គ្រួសារ ក្នុងនោះផ្តល់បង្គន់គ្រួសារចំនួន ២៤០គ្រួសារ និង កន្លែងលាងសម្អាតដៃ ចំនួន ៥៣៥ កន្លែង។



*រូបភាពដកស្រង់ពីPage Facebook សម្តេចតេជោនាយករដ្ឋមន្ត្រី*

[៧] ប្រភព៖ ក្រសួងសុខាភិបាល។

នៅក្នុងខេត្តត្បូងឃ្មុំបានផ្តល់បង្គន់អនាម័យ គ្រួសារចំនួន២៣៥ ជូនប្រជាពលរដ្ឋក្នុងភូមិគោលដៅ។ នៅខេត្តសៀមរាប បាត់ដំបង ព្រះវិហារ និងកោះកុង ក្នុងស្រុកចំនួន៨ ឃុំចំនួន២០ ភូមិចំនួន៣៨ អនុវត្តដោយអ្នកស្ម័គ្រចិត្តចំនួន១៣៦នាក់ និងមានអ្នកទទួលផលសរុបចំនួន៣៣.៣៩៩គ្រួសារ ក្នុងនោះផ្តល់បង្គន់អនាម័យគ្រួសារចំនួន២៩ និងតាមសាលារៀនជូនប្រជាពលរដ្ឋក្នុងសហគមន៍ ផ្តល់អណ្តូងទឹកចំនួន៨អណ្តូងដល់សហគមន៍ និងមួយអណ្តូងជូនសាលារៀន ព្រមទាំងផ្តល់កញ្ចប់អាហារូបត្ថម្ភជូនកុមារ១២០កញ្ចប់ បញ្ជូនស្ត្រីមានផ្ទៃពោះចំនួន១៥៥នាក់ទៅពិនិត្យសុខភាព បញ្ជូនកុមារអាយុក្រោម៥ឆ្នាំចំនួន៣៣៤នាក់ទៅពិនិត្យសុខភាព ផ្សព្វផ្សាយអំពីអនាម័យការប្រើប្រាស់ទឹកស្អាត សម្អាតបរិស្ថាន និងការលាងដៃ។ នៅខេត្តក្រចេះ ស្វាយរៀង និងបន្ទាយមានជ័យ ក្នុងស្រុក/ក្រុងចំនួន៣ ឃុំចំនួន៧ ភូមិចំនួន៣៣ អនុវត្តដោយយុវជន ចំនួន១០០នាក់ អ្នកស្ម័គ្រចិត្តចំនួន៩៦នាក់ និងមានអ្នកទទួលផលសរុបចំនួន១៩.៤៦២គ្រួសារ ក្នុងនោះបានផ្តល់បង្គន់អនាម័យគ្រួសារចំនួន៣៨៩បង្គន់ អណ្តូងស្នប់ចំនួន១០អណ្តូង ប្រព័ន្ធទឹកស្អាតចំនួន២សម្រាប់ ម៉ាស៊ីនចម្រោះទឹកស្អាតចំនួន៦គ្រឿង សម្ភារៈអនាម័យចំនួន២៨កញ្ចប់។

ទន្ទឹមនឹងនោះដែរ កាកបាទក្រហមកម្ពុជា មានគម្រោងទឹកស្អាត និងអនាម័យ ដោយបានផ្តល់អណ្តូងទឹកចំនួន១៦៨ ស្រះទឹក១៨ និងស៊ីទែនទឹក៧ សម្រាប់អ្នកទទួលផល១០.២៤៥គ្រួសារ នៅខេត្តចំនួន១២ ដែលប្រឈមនឹងកង្វះទឹកស្អាតសម្រាប់បរិភោគ និងប្រើប្រាស់។ ព្រមជាមួយនេះ កាកបាទក្រហមកម្ពុជាក៏បានផ្តល់ថវិកាជួយដល់មន្ទីរពេទ្យគន្ធបុប្ផា ក្នុងគោលបំណងថែទាំ និងព្យាបាលជំងឺដល់កុមារ។[៨]

## ២- សិទ្ធិអភិវឌ្ឍន៍[៩]

**អនុសាសន៍ទី៧ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*បន្តលើកកម្ពស់គុណភាពវិស័យអប់រំ ដោយខិតខំបង្កើនអត្រាកុមារចូលរៀនឲ្យបានខ្ពស់ថែមទៀត កាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា បង្កើនចំនួនសាលាកុមារមេត្រី ពង្រឹងកម្មវិធីអប់រំក្រៅប្រព័ន្ធ កម្មវិធីអប់រំបំពេញលក្ខ និងបង្កើនការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រចំពោះក្រុមកុមារដែលបាត់បង់ឱកាសនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ពង្រឹងតួនាទី និងការទទួលខុសត្រូវសហគមន៍ ចូលរួមលុបបំបាត់អំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន និងពលកម្មកុមារគ្រប់រូបភាពនៅក្នុងសាលារៀន សហគមន៍ គ្រឹះស្ថាន សិក្សា និងតាមផ្ទះ។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី១៖ លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលជំនាញ) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**២៤**-ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តសកម្មភាពទទួលបាននូវលទ្ធផល រួមមាន៖

**ក-កុមារទទួលបានសេវាអប់រំកុមារតូចតាមគ្រប់រូបភាព**

[៨] របាយការណ៍បូកសរុបសកម្មភាពការងារកាកបាទក្រហមកម្ពុជា ឆ្នាំ២០១៥។

[៩] សិទ្ធិនេះរួមបញ្ចូលអ្វីទាំងអស់ដែលកុមារត្រូវការដើម្បីលូតលាស់ក្នុងកម្រិតខ្ពស់បំផុត និងដើម្បីឲ្យក្លាយទៅជាសមាជិកដែលទទួលខុសត្រូវរបស់ សង្គម។ សិទ្ធិនេះ រួមមានការអប់រំគ្រប់ប្រភេទ និងសិទ្ធិទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ សម្រាប់ការលូតលាស់របស់កុមារ ផ្នែករាងកាយ សតិអារម្មណ៍ ស្មារតី សីលធម៌ និងសង្គម។

ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ កុមារអាយុពី០-៥ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន ៤២៦.០២៥ នាក់ ស្មើនឹង២១,៧៩% នៃចំនួនប្រជាជនអាយុពី០-៥ឆ្នាំ ស្រី២១៤.២៤៩នាក់ ស្មើនឹង ៥០,៣%។ កុមារ អាយុ៣ឆ្នាំ បានទទួលសេវាអប់រំគ្រប់រូបភាពមាន៦៣.៥០៩នាក់ ស្មើនឹង២០,៣% នៃចំនួនប្រជាជន អាយុ៣ឆ្នាំ ស្រី៣២.៨០០នាក់ ស្មើនឹង៥១,៦%។ កុមារអាយុ៤ឆ្នាំ បានទទួល សេវាអប់រំគ្រប់រូបភាពមាន១១៣.០១០នាក់ ស្មើនឹង៣៧,៣៧% នៃចំនួនប្រជាជនអាយុ៤ឆ្នាំ ស្រី ៥៧.៧០៩នាក់ ស្មើនឹង៥១,១%។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាព ១៩៦.៦៦៩នាក់ ស្មើនឹង៦៦,៣%នៃ ចំនួនប្រជាជនអាយុ៥ឆ្នាំ ស្រី៩៧.១២៧នាក់ ស្មើនឹង៤៩,៤%។

**មត្តេយ្យសិក្សារដ្ឋ៖** កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំ១៣.៤៧០នាក់ ស្មើនឹង៤,៣% ស្រី ៧.៤៨៦នាក់។ កុមារអាយុ៤ឆ្នាំ បានទទួលសេវាអប់រំ៥២.៦៩៣នាក់ ស្មើនឹង១៧,៤% ស្រី ២៧.០៤៤នាក់។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំ១២៣.៩៩៥នាក់ ស្មើនឹង៤១,៨% ស្រី ៦០.៩០៦នាក់។

**មត្តេយ្យសិក្សាឯកជន៖** កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំ៦.៨១៥នាក់ ស្មើនឹង២,២% ស្រី ៣.៣៥៨នាក់។ កុមារអាយុ៤ឆ្នាំ បានទទួលសេវាអប់រំ១៥.២៩៤នាក់ ស្មើនឹង៥,១% ស្រី៧.៧១០នាក់។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំ១៦.៣៨០នាក់ ស្មើនឹង៥,៥% ស្រី៧.៨០៣នាក់។

**មត្តេយ្យសិក្សាសហគមន៍៖** កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំ១៩.០៥៩នាក់ ស្មើនឹង៦,១% ស្រី៩.៨៨៥នាក់។ កុមារអាយុ ៤ឆ្នាំ បានទទួលសេវាអប់រំ២៣.៥៤៩នាក់ ស្មើនឹង៧,៨% ស្រី ១២.១២៧នាក់។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំ២២.១៣០នាក់ ស្មើនឹង៧,៥% ស្រី ១១.០៥៩នាក់។

**ការអប់រំកុមារតូចតាមផ្ទះ៖** កុមារអាយុពី០ដល់ក្រោម៣ឆ្នាំ បានទទួលសេវាអប់រំ៥២.៨៣៧ នាក់ ស្មើនឹង៥,១% ស្រី២៦.៦១៣នាក់។ កុមារអាយុ៣ឆ្នាំ បានទទួលសេវាអប់រំ២៤.១៦៥នាក់ ស្មើនឹង៧,៧% ស្រី១២.០៧១នាក់។ កុមារអាយុ៤ឆ្នាំ បានទទួលសេវាអប់រំ២១.៤៧៤នាក់ ស្មើនឹង ៧,១% ស្រី១០.៨២៨នាក់។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំ៣៤.១៦៤នាក់ ស្មើនឹង១១,៥% ស្រី១៧.៣៥៩នាក់។

**កម្មវិធីអប់រំពហុភាសា៖** កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច បានអនុវត្ត ក្នុងក្រុង ស្រុក១៩ នៃខេត្ត គោលដៅ៥ មានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងខេត្ត ក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាសិក្សាមត្តេយ្យសិក្សារដ្ឋ៣កន្លែង មានសិស្ស៩៤នាក់ ស្រី៥១នាក់ និងមត្តេយ្យសិក្សា សហគមន៍៨០កន្លែង មានសិស្ស១.៧៧៤នាក់ ស្រី៧៨៤នាក់។ ភាសាដែលបានប្រើប្រាស់រួមមានភាសាទំពួន គ្រឹង ព្នង ក្ទួយ ក្រោល កាវ៉ែត កាចក់ ព្រៅ...។

**កម្មវិធីមត្តេយ្យសិក្សាចល័ត៖** បានគ្របដណ្តប់លើកុមារមានអាយុពី៣ ទៅ៥ឆ្នាំ រស់នៅតំបន់ ជនជាតិដើមភាគតិច ដែលមានគ្រួសារបម្លាស់ទីលំនៅ និងមានចម្ងាយឆ្ងាយពីសាលាមត្តេយ្យ សិក្សារដ្ឋ ឬមត្តេយ្យសិក្សាសហគមន៍។ កម្មវិធីនេះ អនុវត្តតាមរយៈការចល័តដោយប្រើយានជំនិះ ផ្សេងៗ មាន ២ភូមិ ក្នុងឃុំកោះពាក្យ ស្រុកវើនសៃ និងឃុំតាវែងក្រោម ស្រុកតាវែង និងចល័តតាម រដូវកាលមាន៣ ភូមិ ក្នុងឃុំតាឡាវ ស្រុកអណ្តូងមាស និងឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី។

**កម្មវិធីអប់រំបរិយាបន្ន៖** ការអប់រំបរិយាបន្នសម្រាប់កុមារពិការនៅកម្រិតមត្តេយ្យសិក្សា បានអនុ វត្តនៅខេត្តសៀមរាប បាត់ដំបង កំពង់ធំ ព្រៃវែង រតនគិរី ក្រចេះ និងរាជធានីភ្នំពេញ។ កម្មវិធីនេះ បានអនុវត្តដោយផ្សារភ្ជាប់ជាមួយមត្តេយ្យសិក្សារដ្ឋ១៧៦សាលា មានកុមារ១៦៥នាក់ ស្រី៤៩នាក់។

**លទ្ធផលនៃការសិក្សា៖** កុមារអាយុ៥ឆ្នាំ បានបញ្ចប់ការសិក្សាថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់ ១៧២.០៦៧នាក់ ស្រី៨៥.៥៧៥នាក់។ កុមារចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាបានឆ្លងកាត់សេវាអប់រំកុមារតូចគ្រប់ រូបភាព៦៤%។

សមិទ្ធផលខាងលើបានបង្ហាញថា ការប្រមូលកុមារតូចអាយុ៤ និង៥ឆ្នាំ តាមគ្រប់រូបភាពទទួលបានលទ្ធផលល្អប្រសើរ។ លទ្ធផលនេះ បញ្ជាក់ពីការខិតខំរបស់រាជរដ្ឋាភិបាល សហគមន៍ មាតាបិតា និងអ្នកពាក់ព័ន្ធ តាមរយៈការសង់អគារសិក្សា និងការផ្តល់សម្ភារបរិក្ខារ។ លទ្ធផលដែលទទួលបាន ក្នុងឆ្នាំសិក្សានេះ មានភាពប្រហាក់ប្រហែលនឹងឆ្នាំសិក្សាកន្លងទៅ ដោយសេវានេះ ពុំមានការពង្រីកវិសាលភាពគ្របដណ្តប់តំបន់ជនជាតិដើមភាគតិចនៅឡើយ។ ការអប់រំកុមារតូចនៅតំបន់ជនជាតិដើមភាគតិច ដែលមានទម្រង់ជាថ្នាក់មត្តេយ្យសិក្សាចល័ត ដោយសហការជាមួយដៃគូអភិវឌ្ឍបានផ្តល់ឧត្តមានុវត្តន៍ សម្រាប់អនុវិស័យអប់រំកុមារតូច។

## ខ-កុមារទទួលបានសេវាអប់រំបឋមសិក្សា

សិស្សចូលរៀននៅសាលាបឋមសិក្សារដ្ឋសរុប២.០២២.០៦១នាក់ ស្រី៩៧៤.២៣១នាក់ ស្មើនឹង៤៨,១៨%។ សិស្សបឋមសិក្សាឯកជន៨៩.៥៧០នាក់ ស្រី៤៤.០៩៥នាក់ ស្មើនឹង៤៩,៣%។ អត្រាពិតចូលរៀនថ្មីសរុប៩៥,១% ស្រី៩៤%។ អត្រាពិតចូលរៀនថ្មីរដ្ឋ៩១% ស្រី៩០,១% និងអត្រាពិតចូលរៀន ថ្មីឯកជន៤,១% ស្រី៣,៩%។

**កម្មវិធីអប់រំពហុភាសា៖** កម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច ត្រូវបានអនុវត្តនៅតាមសាលា៨០ មានគ្រូ២១៦នាក់ ស្រី៣៦,១% និងសិស្ស៤.៨១៨នាក់ ស្រី៤៧,៤% ក្នុងស្រុកគោលដៅ១៥ នៃខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ។ កម្មវិធីនេះ គឺជាស្ពានឆ្លងពីភាសាកំណើតទៅភាសាជាតិ និងបានអនុវត្តសម្រាប់៥ភាសា គឺ គ្រឹង ទំពួន ព្នង និងការ៉ែត ពីថ្នាក់ទី១ ដល់ទី៣។

**កម្មវិធីពន្លឿនការសិក្សា៖** កម្មវិធីពន្លឿនការសិក្សាត្រូវបានអនុវត្តក្នុងក្រុង ស្រុក ៧ នៅខេត្តកំពតក្រចេះ និងព្រះវិហារ ក្នុងសាលារៀន១៦ សិស្ស៥០០នាក់ ស្រី៤៨,២% ដោយសហការជាមួយអង្គការយូនីសេហ្វ និងនៅតាម សាលារៀន១៤១ទៀត ក្នុងស្រុកខណ្ឌ៣០ នៃរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ព្រៃវែង ព្រះសីហនុ និងសៀមរាប មានសិស្ស៦.៧៣៣នាក់ ស្រី៤៦,៥៦%។

ថ្នាក់បំប៉នសម្រាប់បង្រៀនសិស្សដែលរៀនយឺត និងកម្មវិធីរៀនសារឡើងវិញសម្រាប់សិស្សបោះបង់ការសិក្សា និងសិស្សធ្លាក់ចំណាត់ថ្នាក់១.៦៤១ថ្នាក់ បានអនុវត្តនៅតាមសាលាបឋមសិក្សា១.០០០ ក្នុងខេត្តសៀមរាប ក្រចេះ ត្បូងឃ្មុំ រតនគិរី កោះកុង និងកំពង់ធំ មានសិស្ស១០.៩៦២នាក់ ស្រី៥០% ដោយសហការជាមួយអង្គការដៃគូ។

កម្មវិធីស្ពានចម្លងសិស្សថ្នាក់ទី៦ទៅទី៧ ផ្តោតលើមេរៀនភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា និងគីមីវិទ្យា ដើម្បីត្រៀមចូលរៀនថ្នាក់ទី៧ មានសិស្ស៨០៦នាក់ ស្រី៤០% និងកម្មវិធីស្ពានចម្លងសិស្សមត្តេយ្យ សិក្សាត្រៀមចូលទី១ មានសិស្ស៧៧២នាក់ ស្រី៤៥,៥%។

កម្មវិធីអំណានដល់កុមារដែលរៀនយឺតមានសិស្ស៤.៤៣១នាក់ ស្រី៤០% នៅសាលាបឋមសិក្សា៦៥០ ក្នុង៩ខេត្ត និងរៀបចំទិវាអំណានជាតិមានសិស្សចូលរួម៣៥.៣៩២នាក់ ស្រី៤៥% ក្នុងស្រុក៤៣ ព្រមទាំងបានផ្តល់បរិក្ខារទឹកស្អាត និងអនាម័យដល់សាលា២០ ដោយសហការជាមួយអង្គការដៃគូ។

**កម្មវិធីអប់រំបរិយាបន្ន៖** កម្មវិធីអប់រំបរិយាបន្ន ត្រូវបានអនុវត្តនៅសាលារៀន៩៨ ក្នុងស្រុក១២ នៃខេត្ត៦ មានសិស្ស១០៥ នាក់ ស្រី៣៥% និងផ្តល់សេវាអប់រំដល់កុមារពិការភ្នែក និង គ ថ្លង់ ក្នុងសាលា

ពិសេស៥ នៅរាជធានី ភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងកំពង់ចាម មានសិស្សពិការ៦៨៨នាក់ ស្រី២៦,៣%។ សេវាអប់រំ ដល់កុមារខ្សោយបញ្ញានៅរាជធានីភ្នំពេញ កណ្ដាល កំពង់ស្ពឺ កំពត ក្រចេះ ប៉ៃលិន សៀមរាប និងពោធិ៍សាត់ បានអនុវត្តនៅសាលារៀន១៦៥ មានសិស្ស១.៧៣៧នាក់ ស្រី ៣៩,៦%។

**កម្មវិធីអាហារូបករណ៍ និងស្បៀងអាហារនៅតាមសាលារៀន៖** ក្រសួងបានផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រក្នុងសាលា៣.២៥៣ ត្រូវជា៩៥,៩% នៃសាលាបឋមសិក្សាទូទាំងប្រទេស សិស្សសរុប ៧៧.៦៥៤នាក់ ស្រី៥៥% ប្រើប្រាស់ថវិកាកម្មវិធី។ អាហារូបករណ៍ជាសាច់ប្រាក់ក្នុងសាលា១.២៥១ ត្រូវជា១៧,៧% នៃសាលាបឋមសិក្សាទូទាំងប្រទេស សិស្សសរុប២៤.៦០០នាក់ ស្រី៥៤,៩% និងអាហារូបករណ៍ជាស្បៀងដល់សាលា៧៦២ ត្រូវជា១០,៨% នៃសាលាបឋមសិក្សាទូទាំងប្រទេសសិស្សសរុប១៥.៨៤៤នាក់ ស្រី៥៦,៦%។

សិស្សក្រីក្រងាយរងគ្រោះ២.៣២៥នាក់ ស្រី៥០% បានទទួលអាហារូបករណ៍ សិស្ស២៨៧.១៣០ នាក់ ស្រី៤៩,៣% នៅតាមសាលារៀន១.១៣៨ បានបរិភោគអាហារពេលព្រឹក និងសិស្ស១២.៦៣២ នាក់ ស្រី៥០% នៃសាលា៥៩ បានបរិភោគអាហារពេលព្រឹក ប្រើប្រាស់កសិផលក្នុងសហគមន៍ សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក។

កុមារលើសអាយុ កុមារមកពីគ្រួសារក្រីក្រ កុមារពិការ កុមារជនជាតិដើមភាគតិច កុមាររស់នៅតាមចិញ្ចើមថ្នល់ក្នុងរាជធានីភ្នំពេញ និង២១ខេត្ត ចំនួន២២.៨៧៨នាក់ ស្រី៤៨% បានទទួលអាហារូបករណ៍ជាថវិកា និងសម្ភារៈសិក្សា ដោយសហការជាមួយគម្រោងដៃគូរួមគ្នា ផ្ដល់ឱកាសអប់រំដល់កុមារបាត់បង់ឱកាសនៅកម្ពុជា។

**អត្រាលំហូរសិស្ស និងអត្រាបញ្ចប់ការសិក្សា៖** អត្រាឡើងថ្នាក់នៅបឋមសិក្សាបានកើនដល់ ៨៨,៧% ស្រី៩១,១% និងប្រុស៨៦,៤%។ អត្រាត្រួតថ្នាក់បានថយមកត្រឹម៦,៦% ស្រី៥,១% និងប្រុស ៨,១%។ អត្រាបោះបង់ការសិក្សាបានថយមកត្រឹម៤,៦% ស្រី៣,៨% និងប្រុស៥,៥%។ អត្រាបញ្ចប់ការសិក្សាបឋមសិក្សាបានថយមកត្រឹម៧៩,៨% និងប្រុស៥,៥%។ អត្រាបញ្ចប់ការសិក្សាបឋមសិក្សាបានថយមកត្រឹម៧៩,៨% ស្រី៨៣,២% និងប្រុស៧៦,៧%។ លំនាំការថយចុះនៃអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា មានសភាពដូចគ្នានៅថ្នាក់ជាតិ តំបន់ប្រជុំជន និងជនបទ។

## គ-កុមារបានទទួលការអប់រំមធ្យមសិក្សាបឋមភូមិ

សិស្សមធ្យមសិក្សាបឋមភូមិរដ្ឋមាន៥៨៥.៩៧១នាក់ (ស្រី៥១,៨%)។ សិស្សមធ្យមសិក្សាបឋមភូមិឯកជនមាន២២.៩៨៤នាក់ (ស្រី៤៩,៤៧%)។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ៥៧,៦% (ស្រី៦១,៥%) ក្នុងនោះអត្រារួមនៃការសិក្សាមធ្យមសិក្សាបឋមភូមិរដ្ឋ៥៥,៧% ស្រី ៥៩,៦% និងអត្រារួម នៃការសិក្សាមធ្យមសិក្សាបឋមភូមិឯកជន១,៩% (ស្រី១,៩%)។ អត្រាឆ្លងភូមិសិក្សាកម្រិតមធ្យមសិក្សា បឋមភូមិ៨៥,៥% (ស្រី៨៨,៩%)។

កម្មវិធីផ្ដល់អាហារូបករណ៍សិស្សក្រីក្រមធ្យមសិក្សាបឋមភូមិ បានគ្របដណ្ដប់លើសាលារៀន ៨០៩ ដែលមានសិស្សអាហារូបករណ៍៦៩.៥១៤នាក់ (ស្រី៦០%)។[១០]

**២៥**-ក្រសួងកិច្ចការនារីបានរៀបចំយុទ្ធសាស្ត្រស្ដីពីការចិញ្ចឹមកូនបែបវិជ្ជមាន ហើយបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍចំនួន១៣ ដែលមានសមាជិកសរុប២៥រូប រៀបចំឧបករណ៍

[១០] ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា។

សម្រាប់បណ្តុះបណ្តាល និងឧបករណ៍ផ្សព្វផ្សាយកម្រិតទី១ កម្រិតទី២ ឆ្នាំ២០១៧-២០២១ ត្រូវបានរៀបចំរួចរាល់ ក្នុងគោលបំណងដើម្បីលើកកម្ពស់ទម្រង់ហិង្សាដោយអនុវត្តវិន័យបែបវិជ្ជមានលើកុមារ ការការពារកុមារពីអំពើហិង្សា និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិនចាំបាច់។[១១]

## ៣- សិទ្ធិទទួលបាននូវការការពារ[១២]

**អនុសាសន៍ទី២ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៦៖**
*ជំរុញការរៀបចំផែនការសកម្មភាពស្តីពីការទប់ស្កាត់ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ ឱ្យបានឆាប់ និងអនុវត្តផែនការសកម្មភាពនេះឱ្យមានប្រសិទ្ធភាព។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី៣៖ ពង្រឹងការការពារកុមារ និងការបង្ការទប់ស្កាត់) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

២៦-ក្រសួងកិច្ចការនារី បានសម្របសម្រួលរៀបចំផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា ដើម្បីឆ្លើយតបនឹងការការពារកុមារពីអំពើហិង្សាឲ្យកាន់មានប្រសិទ្ធភាព។ ផែនការនេះមានគោលបំណង បង្ការទប់ស្កាត់ នឹងឈានទៅរកការលុបបំបាត់អំពើហិង្សាលើកុមារ ដើម្បីលើកកម្ពស់ឧត្តមប្រយោជន៍ របស់កុមារប្រកបដោយប្រសិទ្ធភាព និងចីរភាព។

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ ក្រសួងកិច្ចការនារី បានដាក់ចេញ "គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយែនឌ័រ សម្រាប់យកទៅប្រើប្រាស់ដោយភ្នាក់ងារផ្តល់សេវាពាក់ព័ន្ធនានា រួមទាំងភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដើម្បីបង្កើនគុណភាពសេវាកម្មស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាពាក់ព័ន្ធនឹងយែនឌ័រ។ សៀវភៅគោលការណ៍ណែនាំនេះ រៀបរៀងឡើងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រទី២ "ការការពារផ្នែកច្បាប់ និងសេវាកម្ម" នៃផែនការសកម្មភពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨ ស្របតាមផែនការយុទ្ធសាស្ត្រដើម្បីសមភាពយែនឌរ័ និងការបង្កើនភាពអង់អាចដល់ស្ត្រីនៃផែនការយុទ្ធសាស្ត្រនារីរតនៈទី៤របស់ក្រសួងកិច្ចការនារី ដែលរៀបចំឡើងដើម្បីធានាដល់ស្ត្រី និងក្មេងស្ត្រី ក្នុងការទទួលបាននូវកិច្ចការពារផ្លូវច្បាប់ដោយស្មើភាព។ គោលការណ៍ណែនាំនេះ ជាការបំពេញបន្ថែមទៅលើច្បាប់ដែលនៅជាធរមាន ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រី ជាពិសេសច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ ការរៀបចំគោលការណ៍ណែនាំនេះ បានបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តនូវគោលនយោបាយជាតិ និងច្បាប់នានា ឲ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធមនុស្សផងដែរ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានសម្របសម្រួលផ្តល់សេវាផ្នែកច្បាប់ជូនស្ត្រីរងគ្រោះដោយអំពើហិង្សាតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ នៃមន្ទីរកិច្ចការនារីរាជធានីខេត្តចំនួន៨៧ករណី

[១១] ប្រភព៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។
[១២] សិទ្ធិនេះ រួមមានការការពារពីការរើសអើងពីការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ច ការការពារកុមារដែលគ្មានគ្រួសារ និងការការពារកុមារជាជនភៀសខ្លួន។

រួមមានអំពើហិង្សាក្នុងគ្រួសារ៣៣ករណី រំលោភសេពសន្ថវៈ៥៣ករណី និងករណីប្រទូសកេរ្តិ៍ខ្មាស ០១ករណី ក្នុងនោះជនរងគ្រោះជាអនីតិជន ៤០ ករណី។ ដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរ មានសមត្ថកិច្ច និងតុលាការ មន្ត្រីនគរបាលយុត្តិធម៌ បានពន្លឿនករណីអំពើហិង្សាលើស្ត្រី និង កុមារ ជាពិសេសករណីនៃការបញ្ជូនសំណុំរឿងអនីតិជនទៅស្ថាប័នតុលាការតាមនីតិវិធីច្បាប់។

២៧-ក្រសួងសុខាភិបាលបានបន្តផ្សព្វផ្សាយ "គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាល ស្តីពីការគ្រប់គ្រងអំពើហឹង្សាលើស្ត្រី និងកុមារ" (ដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការចាប់ពីឆ្នាំ ២០១៤ មក) និងបានរៀបចំ "សៀវភៅស្តីពីការថែទាំសុខភាពកុមាររងគ្រោះដោយសារអំពើហិង្សា ឬរំលោភបំពានផ្លូវភេទ" ដែលត្រៀមផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១៧ និងរៀបចំបណ្តុះបណ្តាលបុគ្គលិក ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

២៨- កាកបាទក្រហមកម្ពុជា បានបញ្ច្រៀកគ្រប់សកម្មភាពគម្រោងពាក់ព័ន្ធនឹងការការពារកុមារ ហើយ បានបង្កើតនូវគោលនយោបាយការពារកុមារ។

**អនុសាសន៍ទី៣ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៦៖**

*បន្តអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព និងបន្តផ្សព្វផ្សាយឱ្យបានទូលំទូលាយពីបញ្ហាផលប៉ះពាល់នៃការប្រើប្រាស់ គ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយនានា រួមទាំងទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ(យុទ្ធ សាស្ត្រទី៣៖ ពង្រឹងការការពារកុមារ និងការបង្ការទប់ស្កាត់) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

២៩-ក្រសួង ស.អ.យ បានធ្វើបច្ចុប្បន្នភាពទិន្នន័យអនីតិជនដែលជាប់ឃុំនៅមណ្ឌលអប់រំ កែប្រែ និង ពន្ធនាគារបានចំនួន៧៥៧នាក់ និងសមាហរណកម្ម៩៨នាក់។ អនីតិជនចំនួន១១២នាក់ បានទទួល ការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ដូចជា ជួសជុលម៉ូតូ កាត់សក់ កាត់ដេរ និងកែសម្ផស្ស។ បាន និងកំពុងកសាងមជ្ឈមណ្ឌលអប់រំ កែប្រែ និងបន្សាបគ្រឿងញៀនមួយកន្លែងទៀតនៅខេត្តកំពត។ បានពិនិត្យ កែសម្រួលគោលការណ៍ណែនាំស្តីពីការព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម អ្នកញៀនគ្រឿងញៀន នៅមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំបង្កើតមជ្ឈមណ្ឌល សម្រាប់ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ មជ្ឈមណ្ឌលអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាបណ្តោះអាសន្នរបស់រដ្ឋទាំង០៧កន្លែង និងមជ្ឈមណ្ឌលជាតិព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន បានទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿង ញៀនសរុបចំនួន៥.២០៣នាក់ ស្រី២២៩នាក់ ក្នុងនោះមជ្ឈមណ្ឌលជីវិតថ្មីភ្នំបាក់បន្ទាយមានជ័យ ៨៣១នាក់ មជ្ឈមណ្ឌលឱកាសខ្ញុំរាជធានីភ្នំពេញ២.៧៧៤នាក់ មណ្ឌលពិភពនៃក្តីសង្ឃឹមខេត្តបាត់ដំបង ១៩៨នាក់ មណ្ឌលបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង២៧៥នាក់ មជ្ឈមណ្ឌលកងរាជអាវុធ ហត្ថខេត្តបន្ទាយមានជ័យ៤៩១នាក់ មជ្ឈមណ្ឌលស្តារនីតិសម្បទាខេត្តសៀមរាប៣៥៣នាក់ មជ្ឈ- មណ្ឌលកងរាជអាវុធហត្ថខេត្តព្រះសីហនុ១១២នាក់ និងមជ្ឈមណ្ឌលជាតិព្យាបាលស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន១៥៩នាក់។ បានចេញប្រកាសបញ្ចូលជនរងគ្រោះដោយសារការប្រើប្រាស់ គ្រឿងញៀនចំនួន៣.៧៣៤នាក់ និងប្រកាសបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿង ញៀនចំនួន២.៨៥១នាក់។ ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀននៅសល់ជាក់ស្តែង

ចំនួន២.៣៥២នាក់ (ស្រី១១៨នាក់)។ បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនចំនួន៤៩៧នាក់ មានជំនាញកាត់ដេរ២១០នាក់ សម្អាងការ៧០នាក់ កំព្យូទ័រ១១២នាក់ សិប្បកម្មកៅអីថ្មនិងស្វនរូប៤៥នាក់ និងថ្នាក់អក្ខរកម្ម៦០នាក់។ ក្រៅពីនេះ មជ្ឈមណ្ឌលមានកម្មវិធីសិក្សាភាសាអង់គ្លេស កីឡា និងជំនាញកសិកម្មផងដែរ។[១៣]

៣០-មន្ត្រីអគ្គនាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម បានចូលរួមសហការទប់ស្កាត់ការធ្វើចរាចរសារធាតុញៀនចំនួន០៣ករណី (នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ០២ករណី និងអាកាសយានដ្ឋានសៀមរាប០១ករណី) ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន០៤នាក់ និងរឹបអូសសារធាតុគីមីសម្រាប់ផលិតគ្រឿងញៀន និងសារធាតុញៀនប្រភេទកូកាអ៊ីនសរុបចំនួន៨.៦១៨,៥១ក្រាម។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានកាំកុងត្រូល បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានសិក្សានានា និងមន្ទីរអប់រំរាជធានី ខេត្ត ក្នុងឆ្នាំ២០១៦នេះ បានបន្តចុះផ្សព្វផ្សាយអំពីផលវិបាកដែលបង្កឡើងពីការប្រើប្រាស់គ្រឿងញៀន តាមបណ្តាគ្រឹះស្ថានសិក្សានៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត បានចំនួន៣៦លើក ដោយមានសិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ ចូលរួមសរុបចំនួន២០.៦៤៤នាក់។

**អនុសាសន៍ទី៤ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*ជំរុញការរៀបចំផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (ឆ្នាំ២០១៦-២០២៥) និងចាត់វិធានការឲ្យមានប្រសិទ្ធភាពដល់ការបង្ការ ទប់ស្កាត់ ការដកហូត ការផ្តល់ជំនាញវិជ្ជាជីវៈនិងការស្តារនីតិសម្បទា និងការលើកកម្ពស់ការ*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី៣៖ ពង្រឹងការការពារកុមារ និងការបង្ការទប់ស្កាត់) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

៣១-រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាសេនាធិការ បានខិតខំយ៉ាងពេញទំហឹងក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ក្នុងនោះផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ (ឆ្នាំ២០១៦-២០២៥) បានទទួលការឯកភាពពីរាជរដ្ឋាភិបាលនៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦។ ផែនការជាតិនេះ មានគោលបំណងធានាការពារ និងលើកកម្ពស់សិទ្ធិកុមារជាមូលដ្ឋាន ជាពិសេសការផ្តល់កាលានុវត្តភាពដើម្បីអភិវឌ្ឍកុមារ។ ទន្ទឹមនឹងនេះ ផែនការជាតិមានចរិកលក្ខណៈពហុវិស័យ ដោយអនុវត្តបទអន្តរាគមន៍តាមរយៈអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ និងការចូលរួមសហការពីគ្រប់ភាគីទាំងឡាយ ដែលផ្តោតទៅលើការសង្គ្រោះកុមារឱ្យរួចផុតគ្រោះថ្នាក់ពីការងារ ភាពងាយរងគ្រោះ និងការផ្តល់ឱកាសអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រជីវភាព បង្កើតការងារ និងឱកាសសេដ្ឋកិច្ចដទៃទៀត។

ដើម្បីពង្រឹងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្រសួងបានផ្តោតលើគោលការណ៍ចម្បង ៣ គឺ៖ (១)- ការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឱ្យកុមារទទួលបានការ

[១៣] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧ របស់ក្រសួង ស.អ.យ។

អប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងធ្វើសមាហរណកម្មកុមារទៅក្នុងសង្គមជាតិ (២)-កិច្ចសហការជាមួយសង្គមស៊ីវិលនានា និងការងារប្រយុទ្ធប្រឆាំងការជួញដូរស្ត្រីនិងកុមារ (៣)-ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពការងារកុមារ។ ជាលទ្ធផល ក្នុងឆ្នាំ២០១៦នេះ ក្រសួង សម្រេចបាននូវសមិទ្ធផលដូចមានក្នុងតារាងលម្អិតខាងក្រោម៖

**តារាង៖ ការធ្វើអធិការកិច្ចពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថាន**

| បរិយាយ | ឯកតា | ២០១៥ | ២០១៦ | បម្រែបម្រួល ២០១៦-២០១៥ |
|---|---|---|---|---|
| ចុះធ្វើអធិការកិច្ចការងារតាមរោងចក្រដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិកវ័យ ក្មេង | លើក | ១៤ | ២៦ | ៨៥.៧% |
| ចុះធ្វើអធិការកិច្ចការងារកុមារជាមួយអង្គការ ILO | លើក | ៧ | ៤ | -៤២.៩% |
| | សហគ្រាស | ៧ | ៤ | -៤២.៩% |
| | សរុប (នាក់) | ១៥ | ៧ | -៥៣.៣% |
| | ស្រី (នាក់) | ១៥ | ៧ | -៥៣.៣% |
| សហគ្រាសដែលបានស្នើសុំប្រើប្រាស់កម្មករវ័យក្មេង | សហគ្រាស | ១៤ | ២៦ | ៨៥.៧% |
| | សរុប (នាក់) | ៥៥៩ | ១,៤៦៦ | ១៦២.៣% |
| | ស្រី (នាក់) | ២១៦ | ១,៤៦៦ | ៥៧៨.៧% |
| រោងចក្រសហគ្រាសដែលប្រើប្រាស់កម្មករនិយោជិតវ័យក្មេងស្របតាមគោលការណ៍ | សហគ្រាស | ១៩ | ៥៧ | ២០០.០% |
| | សរុប (នាក់) | ៤០១ | ៦៣៥ | ៥៨.៤% |
| | ស្រី (នាក់) | ៣៧៦ | ៦១៩ | ៦៤.៦% |
| ក្រសួងអនុញ្ញាតឱ្យសហគ្រាសប្រើប្រាស់កម្មករនិយោជិតវ័យក្មេង | សហគ្រាស | - | ២១ | - |
| | សរុប (នាក់) | - | ១,៥៥០ | - |
| | ស្រី (នាក់) | - | ១,៥៥០ | - |

ប្រភព៖ នាយកដ្ឋានការងារកុមារ ឆ្នាំ២០១៦

**តារាង៖ ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារដែលចូលរួមសកម្មភាពសេដ្ឋកិច្ច**

| បរិយាយ | ឯកតា | ២០១៥ | ២០១៦ | បម្រែបម្រួល ២០១៦-២០១៥ |
|---|---|---|---|---|
| ចំនួនកុមារដកហូត | សរុប(នាក់) | ៩៤៦ | ១,១៩៨ | ២៦.៦% |
| | ស្រី(នាក់) | ៤៦១ | ៨៣៩ | ៨២.០% |
| ចំនួនកុមារទប់ស្កាត់ | សរុប(នាក់) | ១,៧៦២ | ២,២២៣ | ២៦.២% |
| | ស្រី(នាក់) | ៨៧៨ | ១,៥៥៦ | ៧៧.២% |
| បណ្តុះបណ្តាលគ្រូបង្គោល | វគ្គ | ៣ | ៣ | ០.០% |
| | សរុប (នាក់) | ១៧២ | ១៣៧ | -២០.៣% |
| | ស្រី (នាក់) | ៤៧ | ២៥ | -៤៦.៨% |

ប្រភព៖ នាយកដ្ឋានការងារកុមារ ឆ្នាំ២០១៦

**៣២**-ដើម្បីឆ្លើយតបនឹងតួនាទីរបស់ខ្លួនដែលរាជរដ្ឋាភិបាល បានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦។ បច្ចុប្បន្ន គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារបាន និងកំពុងពង្រឹងយន្តការរបស់ខ្លួន ព្រមទាំងអនុវត្តផែនការសកម្មភាពជាតិ ដើម្បីទប់

ស្គាត់ និងការពារកុមារពីគ្រប់ទម្រង់នៃពលកម្មកុមារ ក្នុងន័យផ្តល់ឱកាសឱ្យកុមារ និងក្រុមគ្រួសាររបស់ពួកគេឱ្យទទួលបានការអប់រំ បណ្តុះបណ្តាលជំនាញ និងបង្កើនជីវភាពរស់នៅ។

៣៣-ក្រសួងពាណិជ្ជកម្ម បានអនុវត្តនូវកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC) ដោយសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការពលកម្មអន្តរជាតិ (ILO) និងសមាគមន៍រោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដើម្បីត្រួតពិនិត្យលើលក្ខខណ្ឌការងាររបស់កម្មករកម្មការនីនៅតាមរោងចក្រ និងពលកម្មកុមារផងដែរ។

៣៤-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានយកចិត្តទុកដាក់ខ្ពស់ទៅលើបញ្ហាកុមារនៅតាមបណ្តារោងចក្រ សិប្បកម្ម ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួង ហើយតាមរយៈការអនុវត្តតួនាទីរបស់ខ្លួន ក្រសួងបានជំរុញឱ្យសហគ្រាសកម្មន្តសាល មុននឹងជ្រើសរើសបុគ្គលិក កម្មករ ចូលបម្រើការងារ ត្រូវពិនិត្យអាយុឱ្យស្របតាមច្បាប់ស្តីពីការងារ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

៣៥-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសាលាជំនាញចំនួន២ ដែលបណ្តុះបណ្តាលមនុស្សលើឯកទេសជំនាញសិល្បៈវប្បធម៌។ សាលាមធ្យមវិចិត្រសិល្បៈ៖ មានទិសដៅសំខាន់សំដៅលើការបណ្តុះបណ្តាលដល់សិស្សានុសិស្ស ដែលមាននិស្ស័យខាងសិល្បៈវប្បធម៌ដែលមានអាយុចាប់ពី៩ឆ្នាំចូលសិក្សាចាប់ពីកម្រិតភូមិសិក្សាថ្នាល រហូតដល់ប្រឡងយកស្លាកបត្រសិល្បៈ ដើម្បីឱ្យក្លាយទៅជាសិល្បករ វិចិត្រករ គ្រូជំនាញ រួមចំណែកអភិវឌ្ឍន៍ និងអភិរក្សសិល្បៈ វប្បធម៌ខ្មែរ ដែលដូនតាយើងបានបន្សល់ទុកជាយូរលង់ណាស់មកហើយ។ សាលាជំនាញចំនួន០៥ មានដូចជា៖ សាលារបាំ៣៧២នាក់ (ស្រី២៨៧នាក់), សាលាតូរ្យតន្ត្រី២៧៤នាក់ (ស្រី៥៩នាក់), សាលាសិល្បៈសូនរូប៩៩នាក់ (ស្រី២៦នាក់), សាលាល្ខោន៥៦នាក់ (ស្រី២៤នាក់) និង សាលាសៀក២៣នាក់ (ស្រី០៨នាក់) សរុបទាំងអស់៨២៤នាក់ (ស្រី៤០៤នាក់)។

បច្ចុប្បន្ន សិស្សដែលកំពុងស្នាក់នៅក្នុងអន្តេវាសិកដ្ឋានមានចំនួន១៧៦នាក់ (ស្រី៥៦នាក់)។ នៅពេលបញ្ចប់ការសិក្សានៅសាលាមធ្យមសិក្សា សិស្សអាចប្រឡងចូលរៀនបន្ត ទៀតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលបណ្តុះបណ្តាលធនធានមនុស្សលើជំនាញសិល្បៈវប្បធម៌។ ដើម្បីក្លាយជាយុវសិល្បករ ជាអ្នកបន្តវេនប្រកបដោយសមត្ថភាព ទេពកោសល្យ ស្នាដៃ មានសក្តានុពល ធានារ៉ាប់រងដល់ការអភិរក្ស អត្តសញ្ញាណជាតិ អភិវឌ្ឍវិស័យសិល្បៈវប្បធម៌។

តាមរយៈការទទួលយកការសិក្សាលើជំនាញសិល្បៈវប្បធម៌នេះ កុមារបានចូលរួមក្នុងការលើកកម្ពស់ការផ្សព្វផ្សាយ ការសម្តែងក្នុងកម្មវិធីផ្សេងៗទាំងក្នុងប្រទេស និងក្រៅប្រទេស។ សិល្បៈវប្បធម៌ជាផ្នាក់ទំនាក់ទំនងរវាងកិច្ចសហប្រតិបត្តិការប្រទេស និងប្រទេស ពីសហគមន៍មួយទៅសហគមន៍មួយ ពីសាលារៀនមួយទៅសាលារៀនមួយទៀត គឺមានការចូលរួមធ្វើសកម្មភាពយ៉ាងច្រើនពីសំណាក់កុមារ ជាពិសេសភាពសប្បាយរីករាយ ធ្វើឱ្យកុមារមានទំនាក់ទំនងល្អជាមួយគ្នា ចេះស្រឡាញ់គ្នា សាមគ្គីគ្នា ក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ ពលរដ្ឋល្អ និងជួយរៀបចំដំណើរជីវិតកុមារដែលសិក្សាលើជំនាញនេះ បច្ចុប្បន្ន និងអនាគត យកអាជីពនេះដើម្បីប្រកបចិញ្ចឹមជីវិតរហូតដល់ខ្លួនធំ ចាកផុតពីអំពើអបាយមុខនានា និងចៀសផុតពីគ្រឿងញៀន និងការជួញដូរកុមារ ការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។[១៤]

[១៤] ប្រភព៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**អនុសាសន៍ទី៥ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*ពង្រឹងប្រព័ន្ធការការពារកុមារឲ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ការអនុវត្តសិទ្ធិកុមារប្រកបដោយប្រសិទ្ធភាព។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី៣៖ ពង្រឹងការការពារកុមារ និងការបង្ការទប់ស្កាត់) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**៣៦**-ក.ជ.ក បានបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ តាមរយៈសេចក្តីសម្រេចលេខ១០៥ ក.ជ.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ក្នុងគោលបំណងដើម្បីសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍ និងផ្នែកឯកជន ក្នុងគោលបំណងពង្រឹងប្រព័ន្ធការពារកុមារ ដើម្បីបង្ការ ទប់ស្កាត់ ការពារ និងលុបបំបាត់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗ និងអំពើហិង្សាលើកុមារ សំដៅបម្រើឧត្តមប្រយោជន៍កុមារ។ គណៈកម្មការមានសមាសភាពដឹកនាំ ដោយប្រធាន០១រូបមកពីក្រសួង ស.អ.យ អនុប្រធាន០៣រូបមកពី គ.ជ.ប.ជ ក្រុមប្រឹក្សាស្តារ អភិវឌ្ឍវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងអគ្គលេខាធិការដ្ឋាន ក.ជ.ក និងសមាជិក៣២រូបទៀត មកពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ជាលទ្ធផលរួមមាន៖

- បានប្រជុំផ្សព្វផ្សាយសមាសភាពគណៈកម្មការការពារកុមារថ្នាក់ជាតិ នៅទីស្តីការក្រសួង ស.អ.យ និងបានបង្កើតជាបណ្តាញក្រុមទំនាក់ទំនង (WhatsApp group) ដើម្បីចែករំលែកព័ត៌មានឱ្យកាន់តែមានប្រសិទ្ធភាព។
- បានប្រជុំពិភាក្សាជាមួយបណ្តាញអង្គការសង្គមស៊ីវិល (CSOs) ដើម្បីស្វែងយល់ពីលទ្ធផលការងាររបស់សង្គមស៊ីវិលពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងបង្កើនទំនាក់ទំនងកិច្ចសហការគ្នា និងរកវិធីសាស្ត្រជំរុញដំណើរការឱ្យកាន់តែប្រសើរថែមទៀត។
- បានរៀបចំកម្មវិធីពិភាក្សាតុមូលស្តីពីតួនាទីគណៈកម្មការការពារកុមារថ្នាក់ជាតិ សម្រាប់ចាក់ផ្សាយក្នុងឱកាសទិវាកុមារអន្តរជាតិ០១ មិថុនា និងចាក់ផ្សាយនៅទូរទស្សន៍ជាតិកម្ពុជា បានចំនួន០៥លើក។
- បានរៀបចំសិក្ខាសាលាស្តីពីប្រព័ន្ធការពារកុមារ ចំនួន ០២ លើក។
- បានរៀបចំសិក្ខាសាលាស្តីពីការបង្កើតផែនការសកម្មភាព និងផែនការថវិកាសម្រាប់គណៈកម្មការ នៅខេត្តព្រះសីហនុ។
- បានប្រជុំក្រុមការងារចំនួន០៣លើក ដើម្បីពិភាក្សាអំពីគំនិតផ្តួចផ្តើមនៃការបង្កើតក្របខណ្ឌការងារស្តីពីកិច្ចការពារកុមារ។

**៣៧**-ក្រសួងកិច្ចការនារី និងអ្នកពាក់ព័ន្ធ ក្រោមការគាំទ្រដោយអង្គការយូនីសេហ្វ បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពទប់ស្កាត់អាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់ ដើម្បីរួមចំណែកចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចប់អាពាហ៍ពិពាហ៍វ័យកុមារ និងការមាន ផ្ទៃពោះវ័យជំទង់ ដែលជាផ្នែកមួយឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហឹង្សាលើកុមារ តាមរយៈការកាត់បន្ថយការរៀបអាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះវ័យជំទង់នៅសហគមន៍ជនជាតិភាគតិចនៃខេត្តរតនគិរី។

**អនុសាសន៍ទី៩ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ក្នុងតំបន់ និងអន្តរជាតិ ដើម្បីរួមគ្នាដោះស្រាយរាល់បញ្ហានានារបស់កុមារ។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ (យុទ្ធសាស្ត្រទី៤៖ ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ) សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

៣៨-គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សហការជាមួយស្ថាប័នអនុវត្តច្បាប់ មានអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថ អគ្គព្រះរាជអាជ្ញា ក្រសួងមហាផ្ទៃ យុត្តិធម៌ និងស្ថាប័ន តុលាការ បានធ្វើឲ្យការបង្ក្រាបអំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើសទទួលបានលទ្ធល្អគួរជាទីពេញចិត្ត ទាំងបរិមាណនិងគុណភាព ដោយសម្រេចបាននូវសមិទ្ធផលរួមមាន៖

- អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយមានកិច្ចសហការជាមួយព្រះរាជអាជ្ញាតាមបណ្តារាជធានី ខេត្ត សកម្មភាពបង្ក្រាបបានអនុវត្តចំនួន៩២ករណី (លើ១០៥ករណីធៀបឆ្នាំ២០១៥ ថយចុះ១៣ករណី)។ ឃាត់ខ្លួនជនសង្ស័យ និងបញ្ជូនទៅតុលាការបានចំនួន ១១៣/១៩៤នាក់ (ថយចុះចំនួន៣១នាក់) ស្រី៤៦នាក់ អនីតិជន១២នាក់ ត្រូវបានចាប់ខ្លួន។ ក្នុងចំនួនជនសង្ស័យដែលជាជនបរទេសចំនួន០៨នាក់ មាន០៧សញ្ជាតិ៖ អូស្រ្តាលី០១នាក់ ឥណ្ឌា០១នាក់ វៀតណាម០១នាក់ ថៃ០១នាក់ កូរ៉េ០១នាក់ និងហូឡង់០២នាក់។ ដោយឡែកជនរងគ្រោះ ដែលសង្គ្រោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបចំនួន២៩៨ លើ២៩៥នាក់ (កើន០៣នាក់) ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំចំនួន៤៧នាក់ អាយុពី១៥-១៧ឆ្នាំចំនួន៤៤នាក់ អាយុ១៨ឆ្នាំឡើងចំនួន២០៧នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន១៦១នាក់ និងអង្គការដៃគូចំនួន០៧នាក់ និងគ្រួសារ១៣០នាក់។
- ករណីអំពើជួញដូរមនុស្ស៖ បង្ក្រាបបាន២៧/៤៧ករណី (ថយចុះ២០ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន៣៩នាក់ (ស្រី២១នាក់) ក្នុងនោះជនបរទេសចំនួន០៣នាក់ សង្គ្រោះជនរងគ្រោះបានចំនួន១១១នាក់ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| បទល្មើស | ករណី | ជនសង្ស័យ | បរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៦ | ៦ | |
| -ការនាំយកចេញមិនស្របច្បាប់ដោយមានគោលដៅ | ១០ | ១៧ | ប៉ាគីស្ថាន១, ថៃ១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៧ | ១១ | |
| -អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២ | ២ | |
| -ការដឹកជញ្ជូនដោយមានគោលដៅ | ១ | ២ | |
| -ការទិញពេស្យាចារកុមារ | ១ | ១ | កូរ៉េ |
| ***សរុប*** | ***២៧ករណី*** | ***៣៩នាក់*** | ***៣នាក់*** |

ប្រភព៖ គ.ជ.ប.ជ

*បញ្ជីជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖*

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | |
|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅគ្រួសារ |
| ១១១នាក់ | ០៧នាក់ | ២៣នាក់ | ៨១នាក់ | ៧៤នាក់ | ៣៧នាក់ |

ប្រភព៖ គ.ជ.ប.ជ

- អំពើធ្វើអាជីវកម្មផ្លូវភេទ៖ បង្ក្រាបបាន៦៥/៥៨ករណី (កើន០៧ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន៦៦នាក់ ស្រី២៥នាក់ (អនីតិជន០៩នាក់) ក្នុងនោះជនបរទេស០៥នាក់ សញ្ជាតិអូស្ត្រាលី០១នាក់ វៀតណាម ០១នាក់ ឥណ្ឌា០១នាក់ និងហូឡង់០២នាក់) សង្គ្រោះជនរងគ្រោះបានចំនួន១៨៧នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

| បទល្មើស | ករណី | ជនសង្ស័យ | បរទេស |
|---|---|---|---|
| -សញ្ជារកម្ម | ៧ | ១០ | អូស្ត្រាលី១ |
| -សញ្ជារកម្ម (មានអនីតិជន) | ៤ | ៥ | |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ៦ | ៩ | វៀតណាម១ |
| -សញ្ជាកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | ៧ | ៨ | |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ៣ | ៤ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ១ | ១ | ហូឡង់១ |
| -រូបភាព និងសម្ភារៈអាសអាភាសកុមារ | ១ | ១ | ហូឡង់១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ២៥ | ២៥ (អនីតិជន១០នាក់) | ឥណ្ឌា១ |
| -អំពើអាសប្រនាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ (អនីតិជន២នាក់) | |
| សរុប | ៦៥ករណី | ៧៤នាក់ | ៥នាក់ |

ប្រភព៖ គ.ជ.ប.ជ

**បញ្ជីជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖**

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ១៨៧នាក់ | ៤០នាក់ | ២១នាក់ | ១២៦នាក់ | ១២៨នាក់ | ០៧នាក់ | ៥២នាក់ |

ប្រភព៖ គ.ជ.ប.ជ

- ករណីប្រព្រឹត្តអំពើអន្តរការ រវាងអ្នកសុំកូន និងស្ត្រីពពោះ (យោងតាមរបាយការណ៍របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ)៖ បង្ក្រាបបាន០១ករណី ឃាត់ខ្លួនជនសង្ស័យចំនួន០៣នាក់ ស្រី០១នាក់ (អូស្ត្រាលី ០១នាក់) ក្នុងនោះសង្គ្រោះជនរងគ្រោះបានចំនួន១២នាក់។
- ការកសាងសំណុំរឿងបណ្តឹងជនរងគ្រោះបញ្ជូនទៅតុលាការ

| ល.រ | អំពើ | មាត្រា | ចំនួនករណី | | ចំនួនបទល្មើស | | ចំនួនជនរងគ្រោះ | |
|---|---|---|---|---|---|---|---|---|
| | | | ជួញដូរ | ជួញដូរ | ជួញដូរ | ជួញដូរ | ជួញដូរ | ជួញដូរ |

| | | | មនុស្ស | ភេទ | មនុស្ស | ភេទ | មនុស្ស | ភេទ |
|---|---|---|---|---|---|---|---|---|
| ១ | ការនាំយកអនីតិជនចេញដោយ មិនស្របច្បាប់ | ៩* | ៦ | | | ២៩ | ៦ | |
| ២ | | ១០* | ១០ | | | ២២ | ១៧ | |
| ៣ | | ១១* | ៧ | | | ៣៤ | ១១ | |
| ៤ | | ១២* | ០ | | | ០ | ០ | |
| ៥ | | ១៥* | ០ | | | ០ | ០ | |
| ៦ | | ១៦* | ២ | | | ៦ | ២ | |
| ៧ | | ១៧* | ១ | | | ១២ | ២ | |
| ៨ | | ២៦* | | | ៧ | | | ១០ |
| ៩ | | ២៦* | | | ៤ | | | ៥ |
| ១០ | | ២៧* | | | ៦ | | | ៩ |
| ១១ | | ២៨* | | | ៧ | | | ៨ |
| ១២ | | ៣២* | | | ៣ | | | ៤ |
| ១៣ | | ៣៣* | | | ០ | | | ០ |
| ១៤ | | ៣៤* | ១ | | | ៨ | ១ | |
| ១៥ | | ៣៥* | ០ | | | ០ | ០ | |
| ១៦ | | ៣៦* | ០ | | | ០ | ០ | |
| ១៧ | | ៣៩* | | | ១ | | | ១ |
| ១៨ | | ៤១* | | | ១ | | | ១ |
| ១៩ | | ៤១* | | | ២៥ | | | ២៥ |
| ២០ | | ៤១* | | | ១១ | | | ១១ |
| ២១ | | ៤៥* | ០ | | | ០ | ០ | |
| | សរុប | ២១ | ២៧ | ៦៥ | ៣៩ | ៧៤ | ១១១ | ១៨៧ |
| | សរុបរួម | ២១ | ៩២ករណី | | ១១៣នាក់ | | ២៩៨នាក់ | |

ប្រភព៖ គ.ជ.ប.ជ

## ៣៩-កិច្ចការយុត្តិធម៌

- ចំណាត់ការរបស់អយ្យការរាជធានី ខេត្ត រយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ១ឆ្នាំ សរុបមានចំនួន១១៦ករណី ជនរងគ្រោះចំនួន៨៧នាក់ (អនីតិជន ៥៩នាក់) ជនត្រូវចោទមានចំនួន១១៤នាក់ មានអនីតិជន១៧នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន៦៦ករណី តម្កល់ទុកឥតចាត់ការចំនួន០៩ករណី ជម្រះផ្ទាល់០១ករណី និងកំពុងចាត់ការចំនួន៤០ករណី ដូចមានរាយលម្អិតខាងក្រោម៖

| ចំនួន | ចំនួនជនរងគ្រោះ | | ចំនួនជនល្មើស | | ប្រភេទចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|
| ករណី | នីតិជន | អនីតិជន | នីតិជន | អនីតិជន | បញ្ជូន | តម្កល់ទុក | ជម្រះ | កំពុង |

| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ទៅស៊ើបសួរ | ឥតចាត់ការ | ផ្ទាល់ | ចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១១៦ | ០៤ | ២៤ | ០២ | ៥៧ | ៩០ | ០៧ | ១៧ | ០ | ៦៦ | ០៩ | ០១ | ៤០ |
| សរុប | ២៨ | | ៥៩ | | ៩៧ | | ១៧ | | ១១៦ | | | |

ប្រភព៖ គ.ជ.ប.ជ

- ចំណាត់ការរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានី ខេត្ត រយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ១ឆ្នាំ សរុបមានចំនួន៨៤ករណី ជនរងគ្រោះ៩៧នាក់ (អនីតិជន៥០នាក់) ជនត្រូវចោទមានចំនួន១១៣នាក់ (អនីតិជន២២នាក់) នៅក្នុងឃុំចំនួន៤២នាក់ ក្រៅឃុំ៣៨នាក់ និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន១៤ករណី លើកលែងចោទចំនួន០២ករណី និងកំពុងចាត់ការចំនួន៦៨ករណី ដូចមានរាយលម្អិតខាងក្រោម៖

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ឃុំខ្លួន | | នៅក្រៅឃុំ | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| ៨៤ | ២៣ | ២៤ | ១០ | ៤០ | ៦១ | ៣០ | ១៥ | ០៧ | | | | | ១៤ | ០២ | ៦៨ |
| សរុប | ៤៧ | | ៥០ | | ៩១ | | ២២ | | ៤២ | | ៣៨ | | ៨៤ | | |

ប្រភព៖ គ.ជ.ប.ជ

-ចំណាត់ការចៅក្រមជំនុំជម្រះរាជធានី ខេត្ត រយៈពេល៩ខែ និងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ រយៈពេល១ឆ្នាំ សរុបមានចំនួន១៣៨ករណី ជនរងគ្រោះចំនួន១៥០នាក់ (អនីតិជន៧៧នាក់) ជនជាប់ចោទសរុប១៥៥នាក់ (អនីតិជន០១នាក់) នៅក្នុងឃុំ១០៣នាក់ នៅក្រៅឃុំ៤៨នាក់ ចាត់ការរួចចំនួន១៦ករណី និងកំពុងចាត់ការចំនួន១២២ករណី ដូចមានរាយលម្អិតខាងក្រោម៖

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | ប្រភេទចំណាត់ការ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ទោសព្យួរ | ន័យជាប្រាក់ | រួចផុតពីបទចោទ | រលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | | | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ក្នុងឃុំ | | ក្រៅឃុំ | | |
| | | | | | | | | | | | | | | ប្រុស | ស្រី | ប្រុស | ស្រី | |
| ១៣៨ | ០៩ | ៦៤ | ០៥ | ៧២ | ១១៣ | ៤១ | ០១ | ០ | ០១ | | | | ១៦ | ៧៤ | ២៩ | ៣៨ | ១០ | ១២២ |
| សរុប | ៧៣ | | ៧៧ | | ១៥៤ | | ០១ | | ០១ | | | | ១៦ | ១០៣ | | ៤៨ | | |

ប្រភព៖ គ.ជ.ប.ជ

- **កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ៖ ការទទួលជនរងគ្រោះ** គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយបានធ្វើការស្តារនីតិសម្បទាជនរងគ្រោះទៅតាមអង្គការនានា ដើម្បីទទួលពិនិត្យសុខភាព ផ្តល់ប្រឹក្សាសម្រាប់ជម្រើស ឬដោះស្រាយផ្លូវច្បាប់ ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ផ្តល់ការស្នាក់នៅ

និងអាហារ ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ទើបប្រគល់ឲ្យគ្រួសារវិញ សរុបចំនួន១,៣៦២នាក់ (ស្រី៤៦៩នាក់ កុមារ៥៣០នាក់)។

- **កិច្ចការពារកុមារ៖** គណៈកម្មាធិការជាតិ គ.ជ.ប.ជ គណៈកម្មាធិការរាជធានី ខេត្ត និងមន្ទីរ ស.អ.យ រាជធានី ខេត្ត បានសហការជាមួយមណ្ឌលរដ្ឋ និងមណ្ឌលអង្គការនានាជាដៃគូ បានជួយសង្គ្រោះកុមារករណីជួញដូរមនុស្ស ជួញដូរផ្លូវភេទ កេងប្រវ័ញ្ចកម្លាំងពលកម្ម និងបានផ្តល់សេវាស្នាក់នៅបណ្តោះអាសន្ន ក្នុងការគ្រប់គ្រង ថែទាំកុមារ ហើយធ្វើសមាហរណកម្មទៅគ្រួសារវិញ សរុបចំនួន៦៥២នាក់ (កុមារីចំនួន៤៨៨នាក់)។[១៥]

៤០-បណ្តាញទូរស័ព្ទពិសេសរបស់អគ្គស្នងការដ្ឋាននគរបាលជាតិលេខ១២៨៨ និង(០២៣) ៩៩៧ ៩១៩ ទទួលការហៅចូល២៤ម៉ោង ដែលអាចផ្តល់ព័ត៌មានសម្រាប់ការស៊ើបអង្កេត និងបង្ក្រាបទាន់ពេលវេលា និងមានបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា(CHC)លេខ១២៨០ ដែលអាចផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលដោះស្រាយបញ្ហាកុមារបានទាន់ពេលវេលា។ ជាលទ្ធផល អ្នកដែលបានទទួលការប្រឹក្សាយោបល់(PC) ចំនួន១.៤៤៥នាក់ (ស្រី៨៧៨នាក់), អ្នកដែលបានរាយការណ៍ស្តីពីភាពរងគ្រោះរបស់កុមារដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ(TPR) ចំនួន៨៣នាក់ (ស្រី៣៩នាក់), អ្នកទទួលសេវាផ្នែកព័ត៌មាន(WT) ចំនួន១៣.៧២៦នាក់ (ស្រី៦៧២២នាក់), អ្នកដែលបានទទួលសេវាបញ្ជូនទៅអាជ្ញាធរ និងអង្គការពាក់ព័ន្ធចំនួន៥៣នាក់ (ស្រី៣៥នាក់)។[១៦]

៤១-ក្រសួង ស.អ.យ បានរៀបចំផែនការសមាហរណកម្មកុមារចំនួន៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារ និងសហគមន៍ប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦-២០១៨ ឆ្លើយតបនឹងការអនុវត្តផែនការយុទ្ធសាស្ត្រឆ្នាំ២០១៤-២០១៨ របស់ក្រសួង និងអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។ ផែនការនេះ ត្រូវបានធ្វើការផ្សព្វផ្សាយជាផ្លូវការនៅទីស្តីការក្រសួង ស.អ.យ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧។

៤២-នៅឆ្នាំ២០១៦ ក្រសួង ស.អ.យ បានធ្វើការកំណត់ទីតាំងមណ្ឌលថែទាំកុមារ ហើយបានរកឃើញកុមារចំនួន១៦.៥៧៩នាក់ (កុមារី៤៧%) កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារចំនួន៤០៦កន្លែង។ ក្នុងចំណោមមណ្ឌលថែទាំកុមារទាំង៤០៦កន្លែង មានមណ្ឌលថែទាំកុមារចំនួន២៦៧កន្លែង ដែលមានកុមារស្នាក់នៅចំនួន១១.៧៨៨នាក់ ស្ថិតនៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កណ្តាល និងខេត្តព្រះសីហនុ ដែលក្រសួងចាត់ទុកថាជាខេត្តអាទិភាពក្នុងការធ្វើសមាហរណកម្មកុមារពីមណ្ឌល ថែទាំឱ្យបានចំនួន៣០% ទៅគ្រួសារ និងសហគមន៍ពីឆ្នាំ២០១៦ ទៅឆ្នាំ២០១៨។ ក្រសួងស្នើទៅអាជ្ញាធររាជធានី ខេត្តអាទិភាពទាំង៥ ជាពិសេសគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រធានមន្ទីរ ស.អ.យ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ត្រូវសហការគ្នារៀបចំផែនការប្រតិបត្តិថ្នាក់ខេត្ត ដើម្បីគាំទ្រការអនុវត្តផែនការសមាហរណកម្មថ្នាក់ជាតិនេះ ឱ្យទទួលបានជោគជ័យ។

បច្ចុប្បន្នមានកន្លែងថែទាំកុមារចំនួន៦៣៩កន្លែង មានកុមារ និងយុវជនចំនួន២៦.១៨៧នាក់ (ស្រី១២.៥២៦នាក់) ក្នុងនោះមណ្ឌលថែទាំកុមារមានចំនួន៤០៦កន្លែង (កើន១៥៣កន្លែង) មានកុមារសរុបចំនួន១៦.៥៧៩នាក់ (កើន៥.៥៦២នាក់) ក្នុងនោះមណ្ឌលរបស់រដ្ឋមាន២២កន្លែង មាន

[១៥] របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៥ និងទិសដៅឆ្នាំ២០១៦ របស់ គ.ជ.ប.ជ។

[១៦] របាយការណ៍សមិទ្ធផលការងាររបស់បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា (Child Helpline Cambodia) ឆ្នាំ២០១៥។

កុមារ និងយុវជន ១.៣៩៣នាក់ ផ្ទះស្នាក់នៅបណ្តោះអាសន្ន២៥កន្លែង មានកុមារ៦២៨នាក់ ផ្ទះស្នាក់នៅជាក្រុម៧១កន្លែង មានកុមារ១.៥៩២នាក់ ក្រៅពីនោះកុមារមួយចំនួនបានកំពុងស្នាក់នៅអន្តេវាសិកដ្ឋាន ទីវត្តអារាម និងទីកន្លែងសាសនា១៣៧កន្លែង មានកុមារ៧.៣៨៨នាក់។ កុមារកំព្រាទាំងនោះសុទ្ធតែទទួលនូវសេវា ស្នាក់នៅ អប់រំ ចិញ្ចឹមបីបាច់ថែរក្សា បង្កលក្ខណៈឲ្យរៀនសូត្រចំណេះដឹងទូទៅបណ្តុះបណ្តាលវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅរស់នៅតាមគ្រួសារ និងសហគមន៍វិញ។[១៧] ក្រៅពីការថែទាំក្នុងមណ្ឌលកុមារកំព្រា កុមារងាយរងគ្រោះមួយចំនួនបានទទួលការចិញ្ចឹមថែទាំ និងផ្តល់សេវាឧបត្ថម្ភផ្សេងៗទៀតនៅក្នុងសហគមន៍ដោយសាច់ញាតិ គ្រួសារធម៌ គ្រួសារចិញ្ចឹម នៅតាមវត្តអារាម និងតាមកម្មវិធីផ្សេងៗទៀតរបស់អង្គការជាតិ និងអន្តរជាតិនានា។

- បានចេញប្រកាសលុបឈ្មោះកុមារពីបញ្ជីបើកប្រាក់គោលនយោបាយចំនួន១៩១នាក់ និងប្រកាសបញ្ចូលកុមារឲ្យស្នាក់នៅក្នុងមណ្ឌលរដ្ឋ និងទទួលរបបគោលនយោបាយចំនួន៨៩នាក់
- បានធ្វើសមាហរណកម្មកុមារចំនួន៥៩នាក់
- បានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារ SOS ខេត្តកំពត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- បានចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមាររបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលបានចំនួន ២៣៦មណ្ឌល ដែលមានកុមារចំនួន១០.៣៧៨នាក់ (ស្រី៤.៩១០នាក់) ក្នុងនោះមណ្ឌលរដ្ឋចំនួន២២ មានកុមារ១.៦០១នាក់ (ស្រី៧២៤នាក់)។
- បានបិទ និងបង្វែរមណ្ឌល កន្លែងថែទាំ និងមណ្ឌលថែទាំកុមារចំនួន៥៦ទីតាំង និងបានធ្វើសមាហរណកម្មយុវជន និងកុមារទៅសហគមន៍ និងទុកដាក់តាមការថែទាំជំនួស។
- បានចុះពិនិត្យ វាយតម្លៃគុណវុឌ្ឍិអង្គការសុវត្ថិភាពកុមារ០៦អង្គការ និងផ្តល់វិញ្ញាបនបត្រជូនអង្គការចំនួន០៤គឺ អង្គការខេមា អង្គការម្លប់ឫស្សី អង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា និងអង្គការឧបត្ថម្ភគ្រួសារកម្ពុជា។
- បានសមាហរណកម្ម និងបង្រួបបង្រួមកុមារចំនួន៤៦២នាក់ ទៅរស់នៅសហគមន៍ និងគ្រួសារវិញ។
- ការងារសុំកូនក្នុងប្រទេស៖ បានសម្របសម្រួល និងអន្តរាគមន៍ជូនឪពុកម្តាយធម៌ដែលមានបំណងនាំ កូនធម៌កម្ពុជាទៅសម្រាកព្យាបាលជំងឺនៅក្រៅប្រទេសចំនួន០៥ករណី។
- ការងារសុំកូនអន្តរប្រទេស៖ បានទទួលរបាយការណ៍ស្តីពីការវិវត្តន៍របស់កូនសុំចំនួន១៣៣ករណី ក្នុងនោះប្រទេសកាណាដា៩២ករណី អ៊ីតាលីចំនួន១៧ករណី ម៉ាល់តាចំនួន០៣ករណី អូទ្រីស ចំនួន០៧ករណី និងប្រទេសប៊ែលហ្ស៊ិក១៤ករណី។
- ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការធ្វើសមាហរណកម្មជនរងគ្រោះ៖ បានសហការជាមួយសាលាដំបូងរាជធានីភ្នំពេញ ជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទចំនួន២២ករណី មានជនរងគ្រោះ៤៩នាក់ ក្នុងនោះមានករណីជួញដូរមនុស្សទៅប្រទេសចិន០៧ករណី សញ្ញារកម្មដែលមានស្ថានទម្ងន់ទោស០៤ករណី ការរំលោភសេពសន្ថវៈ០៩ករណី និងការនាំចេញខុសច្បាប់០២ករណី។ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្មសរុបចំនួន៨៥៥នាក់ (ស្រី

---

[១៧] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត របស់ក្រសួង ស.អ.យ។

៣៧៣នាក់) មកអប់រំពិគ្រោះយោបល់ និងបញ្ជូនទៅអង្គការដៃគូនានាដើម្បីទទួលសេវាបន្ត ក្នុងនោះរាជធានីភ្នំពេញ២១៥នាក់ ខេត្តសៀមរាប២៨នាក់ មណ្ឌលសំចតប៉ោយប៉ែត១២១នាក់ និងអង្គការដៃគូនានា៩១នាក់។ បានទទួលពលករចំណាកស្រុកពីប្រទេសវៀតណាមចំនួន ១០៩នាក់ (ស្រី៦០នាក់)។ បានធ្វើមាតុភូមិនិវត្តន៍ស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សជាជនជាតិវៀតណាមចំនួន១៤នាក់។ បានសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្មទៅសហគមន៍វិញចំនួន៥៨នាក់ និងបិទករណីចំនួន២០នាក់ (ក្នុងនោះរួមមានកុមារផងដែរ)។[១៨]

- ការងារជនអនាថា៖ មន្ទីរ ស.អ.យ រាជធានី បានទទួលជនអនាថាសរុបចំនួន៩៨៩នាក់ (រួមមានកុមារផងដែរ) មកធ្វើការអប់រំ ពិគ្រោះយោបល់ បណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងសមាហរណកម្មទៅសហគមន៍វិញ។ ដោយឡែក មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញបានគ្រប់គ្រងជនក្រីក្រ និងជនអនាថាគ្មានទីពឹងចំនួន១០៨នាក់។

៤៣-ថ្វីត្បិតកម្ពុជាមិនមែនជាប្រទេសផលិត ឬជាប្រភពគ្រឿងញៀន ប៉ុន្តែកម្ពុជាបាន និងកំពុងរងផលប៉ះពាល់នៃការចរាចរណ៍គ្រឿងញៀនពីតំបន់នានាក្នុងពិភពលោក ជាពិសេសតំបន់ត្រីកោណមាសតាមច្រកភាគខាងជើង និងភាគឦសានប្រទេស។ ដោយសារឥទ្ធិពលនេះ ធ្វើឲ្យការចរាចរណ៍ និងការប្រើប្រាស់គ្រឿងញៀនក្នុងស្រទាប់យុវវ័យនៅកម្ពុជា បានរីករាលដាលគួរឲ្យព្រួយបារម្ភ។ ប៉ុន្តែទោះបីយ៉ាងណាក្តី ដោយអនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាល និងទិសដៅការងារដែលបានកំណត់ក្នុងឆ្នាំ២០១៦កន្លងទៅនេះ ក្រសួងមហាផ្ទៃ បានយកចិត្តទុកដាក់ជំរុញផែនការប្រៀបសមរភូមិគ្រឿងញៀនព្រមៗគ្នានៅគ្រប់ថ្នាក់ទូទាំងប្រទេស ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការជាលក្ខណៈអន្តរជាតិ ផ្លាស់ប្តូរព័ត៌មាន បម្រើឲ្យការតស៊ូប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀនដែលមានលក្ខណៈស្មុគស្មាញ ធ្វើឲ្យកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលល្អគួរកត់សម្គាល់។ ជាក់ស្តែងបង្ក្រាបបាន៣.២៧៥ករណី ឃាត់ខ្លួន៧.១៥៣នាក់ (ស្រី៦៦៣នាក់) និងបង្ក្រាបតាមដីកា២២៩ដីកា ឃាត់ខ្លួន២១៦នាក់ (ស្រី២០នាក់) ក្នុងនោះមានជនបរទេស១៥សញ្ជាតិ មាន១៣៩នាក់ (ស្រី២៩នាក់) រឹបអូសបានសារធាតុញៀនសរុប១០០គ.ក្រ និង២១៦,៣៩ក្រ ព្រមទាំងឧបករណ៍ សម្ភារ មាស ប្រាក់ និងវត្ថុតាងមួយចំនួនទៀត។ ជនល្មើស និងវត្ថុតាង ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត។[១៩]

៤៤-**ការងារបង្ការ ទប់ស្កាត់ និងបង្ក្រាបក្រុមក្មេងទំនើង៖** បង្ក្រាប៨៩៣ករណី ឃាត់ខ្លួន១.៨០០នាក់ ស្រី៦១នាក់ ក្នុងនោះបញ្ជូនមុខសញ្ញាក្មេងទំនើងទៅមណ្ឌលអប់រំ១៦ករណី/៣២នាក់ ទៅសាលាដំបូងរាជធានី ខេត្ត ៥៣០ករណី/៨៦២នាក់ ស្រី៤៧នាក់ និងធ្វើកិច្ចសន្យាអប់រំ៣៤៧ករណី/៩០៦នាក់ ស្រី១៤នាក់។ ចំពោះបញ្ហាក្មេងទំនើង អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចបានបន្តអនុវត្តវិធានការឃោសនាអប់រំជាចំហរតាមសហគមន៍ និងភូមិ ឃុំ និងវិធានការច្បាប់។[២០]

---

[១៨] របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត របស់ក្រសួង ស.អ.យ។

[១៩] របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។

[២០] របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។

**៤៥-ការងារអត្រានុកូលដ្ឋាន៖** ដើម្បីពង្រឹងការអនុវត្តបែបបទនីតិវិធី បែបបទកំណត់ និងបទដ្ឋាននានាពាក់ព័ន្ធការងារអត្រានុកូលដ្ឋាន និងពង្រឹងសមត្ថភាពមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រោមជាតិ ជាពិសេសដើម្បីគាំទ្រ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិរយៈពេល១០ឆ្នាំ ស្តីពីអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃបានបង្កើតឲ្យមានមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ដើម្បីពង្រឹងធានាការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីអត្រានុកូលដ្ឋាន (ដែលកន្លងមក នីតិសម្បទាមន្ត្រីអត្រានុកូលដ្ឋាន មានតែនៅថ្នាក់ឃុំ សង្កាត់ប៉ុណ្ណោះ)។ នៅក្នុងឆ្នាំ២០១៦ ការចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋទូទាំងរាជធានី ខេត្ត បានចំនួន៧១៤.១៥២នាក់ ស្រី៣៤៥.១៨១នាក់។[២១]

៤៦-ក្នុងគោលបំណងជំរុញឱ្យប្រជាជន សិស្ស និស្សិត ដែលជាសរសរស្តម្ភ ជាអ្នកបន្តវេនរបស់ប្រទេសជាតិ និងដើម្បីបង្កើនចំណេះដឹងអំពីតម្លៃសិល្បៈវប្បធម៌ ដើម្បីបណ្តុះក្តីស្រឡាញ់ ការចូលរួមថែរក្សា និងអភិវឌ្ឍកាន់តែស៊ីជម្រៅនូវប្រពៃណី ទំនៀមទម្លាប់ សិល្បៈ វប្បធម៌ជាតិឱ្យស្ថិតស្ថេរគង់វង្សជានិរន្តរ៍ ក្នុងសម័យសកលភាវូបនីយកម្ម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំសកម្មភាព និងព្រឹត្តិការណ៍សំខាន់ៗដូចជា៖

- មហោស្រពសិល្បៈយុវជនទូទាំងប្រទេសបានរៀបចំឡើង ដើម្បីអបអរសាទរទិវាវប្បធម៌ជាតិ ៣មិនា ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" បានបំផុសចលនាយុវសិស្សឱ្យចូលរួមដោយផ្ទាល់ទូទាំង២៥រាជធានី ខេត្ត ដោយមានកិច្ចសហការឧបត្ថម្ភគាំទ្រ និងការចូលរួមយ៉ាងសកម្មពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការនៃមន្ទីរអប់រំ យុវជន និងកីឡា សិស្សានុសិស្សមកពីវិទ្យាល័យ និងអនុវិទ្យាល័យនានា ដើម្បីរួមចំណែកបណ្តុះចំណេះដឹងដល់កុមារឱ្យចេះស្រឡាញ់ និងចូលរួមថែរក្សានូវមរតកដូនតា។
- ក្នុងការលើកកម្ពស់ការយល់ដឹង និងបំផុសនូវការអានសៀវភៅអោយបានច្រើន ដើម្បីជាជំនួយក្នុងការសិក្សារៀនសូត្ររបស់កុមារ ក្រសួងបានរៀបចំពិព័ណ៌សៀវភៅថ្នាក់ជាតិលើកទី៥ ឆ្នាំ២០១៦ ក្រោមប្រធានបទ "បង្កើនការអាន បង្កើនការសរសេរ" ពិព័ណ៌នេះ មានការចូលរួមរាប់ម៉ឺននាក់ពីកុមារផងដែរ។
- ដើម្បីឱ្យមហាជន យុវជន ពិសេសកុមារបានស្គាល់ និងយល់កាន់តែច្បាស់នូវអត្តសញ្ញាណជាតិ តម្លៃនៃវប្បធម៌ បំផុសនូវក្តីស្រឡាញ់ និងចូលរួមឱ្យកាន់តែច្រើនក្នុងការថែរក្សា ការពារ និងផ្សព្វផ្សាយ ក្រសួងបានរៀបចំមហោស្រពសិល្បៈទស្សនីយភាពស្តីពីវង់ភ្លេងអារក្ស សិល្បៈ សូនរូប សិប្បកម្មស្តីពីគំនូរបុរាណ ហានុមានចៃចង់នាងសុវណ្ណមច្ឆា ដណ្តាំស្លូ ម្ហូបអាហារ បង្អែមខ្មែរលើកទី១៧ ការបង្ហាញម៉ូតសម្លៀកបំពាក់ខ្មែរ បង្ហើរខ្លែងលើកទី២០ សិល្បៈកំណាព្យ ចម្រៀងខ្មែរជាសកលលើកទី៤ និងមហោស្រពភាពយន្តខ្នាតខ្លីកម្ពុជាលើកទី១។
- ដើម្បីទទួលបាននូវព័ត៌មានក្នុងវិស័យវប្បធម៌កាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ថែមទៀតនោះ ក្រសួងបានសហការជាមួយក្រសួងព័ត៌មាន ផលិតនូវវីដេអូឯកសារវប្បធម៌ចំនួន៥២ សម្រាប់ចាក់ផ្សាយក្នុងកម្មវិធី "នាទីវប្បធម៌" តាមស្ថានីយ៍ទូរទស្សជាតិកម្ពុជា ក្នុង១សប្តាហ៍២ដង គឺរសៀលថ្ងៃព្រហស្បតិ៍វេលាម៉ោង៥:១៥នាទី និងព្រឹកថ្ងៃសុក្រ វេលាម៉ោង១០:៣០នាទី។[២២]

---

[២១] របាយការណ៍ស្តីពីលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។

[២២] ប្រភព៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**អនុសាសន៍ទី៦ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៦៖**

*ពង្រឹងការអនុវត្តច្បាប់ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយអំពីលិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធស្តីពីការការពារកុមារ ការកាត់បន្ថយ និងការលុបបំបាត់ពលកម្មកុមារ កុមារប្រើប្រាស់សារធាតុញៀន អំពើជួញដូរកុមារ អំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់រូបភាព ការសុំកូនអន្តរប្រទេស។ល។ និងធានាការពារកុមារឲ្យរីកលូតលាស់ មានសុខភាព ពេញលេញ ប្រកបដោយបរិយាកាសល្អ។*

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ យុទ្ធសាស្ត្រទី៤ "ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ" សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**៤៧**-បានរៀបចំពិធីផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ(២០១៦-២០១៨) នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ នៅទីស្តីការក្រសួង ស.អ.យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដែលមានសមាសភាពចូលរួមសរុបចំនួន២៩៤នាក់ (ស្រី១១៦នាក់) ក្នុងគោលបំណងឱ្យក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ បានយល់ជ្រួតជ្រាបអំពីផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ដើម្បីដាក់បញ្ចូលសកម្មភាពនានាដែលមានចែងក្នុងផែនការសកម្មភាពជាតិនេះ ទៅក្នុងផែនការប្រតិបត្តិតាមវិស័យរបស់ខ្លួន។




រូបភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)

៤៨-ក.ជ.ក ដែលមានរចនាសម្ព័ន្ធ នៅទូទាំង២៥រាជធានី ខេត្ត និងមានក្រុមការងារដើម្បីកុមារនៅតាមបណ្តាក្រសួងសមាជិកចំនួន០៩ និងបានអនុវត្តតាមផែនការយុទ្ធសាស្ត្រលើកទី២ រយៈពេល៥ឆ្នាំ (២០១៤-២០១៨) ទទួលបាននូវសមិទ្ធផលសំខាន់ៗ រួមមានៈ

- បានសហការជាមួយក្រសួង ស.អ.យ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ បានរៀបចំខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា ១មិថុនា ក្រោមប្រធានបទ **"រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន"** និងខួបលើកទី១៤ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ក្រោមប្រធានបទ **"រួមគ្នាបញ្ចប់ពលកម្មកុមារនៅក្នុងចង្វាក់ផលិតកម្ម"**។ ទិវានេះបានប្រារព្ធនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ នៅសាលមហោស្រពនៃមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** និងមានការចូល



*រូបភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.)*

រួមពីសមាជិករាជរដ្ឋាភិបាល មន្ត្រីតាមក្រសួង ស្ថាប័ន ភ្ញៀវជាតិ អន្តរជាតិ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស កុមារកំព្រា កុមារអនាថា និងកុមារតាមសហគមន៍សរុបចំនួន៣៤០០នាក់។

- បានរៀបចំវេទិកាកុមារ និងសង្គមស៊ីវិល ជាមួយអ្នកធ្វើគោលនយោបាយ នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់កុមារក្នុងដំណើរការរៀបចំគោលនយោបាយ និងចែករំលែកនូវវឌ្ឍនភាព បញ្ហាប្រឈម និងដំណោះស្រាយទាក់ទងនឹងប្រធានបទទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០១៦ **"រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន"** និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា **"រួមគ្នាបញ្ចប់ពលកម្មកុមារ នៅក្នុងចង្វាក់ផលិតកម្ម"** ដែលមានកុមារ មន្ត្រីរាជរដ្ឋាភិបាល និងអង្គការដៃគូពាក់ព័ន្ធចូលរួមសរុប ២៤៧នាក់ (ស្រី១២២នាក់)។

- បានបោះពុម្ព និងផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប លើរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ។ សារាចរណែនាំនេះ បានចែកផ្សាយដល់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ និងបានរៀបចំពិធីផ្សព្វផ្សាយនៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ដែលមានសមាសភាពចូលរួមមានចំនួន៨៩នាក់(ស្រី៣០នាក់)។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបសិទ្ធិកុមារទៅក្នុងផែនការរបស់ក្រសួង ស្ថាប័ន ដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងចំនួន៣ រួមមាន៖ ក្រសួងកិច្ចការនារី ថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកជំទាវ **អ៊ឹម ស៊ីថៃ** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាអនុប្រធាន ក.ជ.ក. និងមានអ្នកចូលរួមសរុបចំនួន១៥រូប (ស្រី១៤រូប)។ ក្រសួងសុខាភិបាល ថ្ងៃទី០៣-០៤ ខែឧសភា ឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកជំទាវ **តាន់ ឡូចឆេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងមានអ្នកចូលរួមសរុបចំនួន១៣រូប(ស្រី១០រូប)។ ក្រសួង ស.អ.យ ថ្ងៃទី០៥-០៦ ខែឧសភា ឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកជំទាវ **ញ៉ៀប សុភាព** អគ្គលេខាធិការ ក.ជ.ក. និងមានអ្នកចូលរួមចំនួន១៨រូប(ស្រី០៥រូប)។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងការអនុវត្តតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តស្វាយរៀង កាលពីថ្ងៃ២៩-៣០ ខែមីនា ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមសរុបចំនួន៤៣នាក់ (ស្រី២៣នាក់)។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កិច្ចការពារកុមារ និងការចូលរួមរបស់កុមារ ចាប់ពីថ្ងៃ១៦-១៧ ខែមិថុនា ឆ្នាំ២០១៦ នៅក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តស្វាយរៀង ដែលមានអ្នកចូលរួមសរុប ចំនួន៣៩នាក់ (ស្រី១៨នាក់)។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការយល់ដឹងពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងការពង្រឹងការអនុវត្ត និងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តក្រចេះ ពីថ្ងៃទី២២-២៤ ខែមិថុនា ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមមកពីមន្ទីរពាក់ព័ន្ធសរុបចំនួន៤០នាក់ ស្រី១៦នាក់។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបសិទ្ធិកុមារទៅក្នុងផែនការរបស់ក្រសួង ស្ថាប័ន ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០-២១ ខែកញ្ញា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដែលមានអ្នកចូលរួមសរុប៣៨នាក់ (ស្រី១៥នាក់)គោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានក.ជ.ក និងមន្ត្រីនៃមន្ទីរ ស.អ.យ ឱ្យមានចំណេះដឹងស្តីពីសិទ្ធិកុមារ និងមានសមត្ថភាពក្នុងការរៀបចំផែនការសកម្មភាព ពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា។
- បានសហការជាមួយអង្គការភ្លែនអន្តរជាតិ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ចំនួន០២លើក ពាក់ព័ន្ធនឹងប្រព័ន្ធការការពារកុមារ ដែលមានគោលបំណង ១-គាំទ្រឱ្យមានវេទិការជួបជុំគ្នារវាងតំណាងស្ថាប័នរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនដែលធ្វើការងារពាក់ព័ន្ធនឹងកិច្ចការពារកុមារ មកពិភាក្សាដើម្បីរកឱ្យឃើញរួមគ្នានូវយុទ្ធសាស្ត្រក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធការការពារកុមារនៅកម្ពុជា ២-ចែករំលែកនូវទស្សនៈ និងបទពិសោធន៍ ដើម្បីឱ្យបានសម្រេចប្រព័ន្ធកិច្ចការពារនៅកម្ពុជា និង៣-អ្នកចូលរួមយល់ច្បាស់ពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធទាំងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

- បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធទិន្នន័យមូលដ្ឋាន CamInfo ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធទិន្នន័យសូចនាករអភិវឌ្ឍជាតិដល់អ្នកពាក់ព័ន្ធ ដែលមានអ្នកចូលរួមចំនួន៣៩នាក់ ស្រី០៩នាក់ កាលពីថ្ងៃទី០៣-០៤ ខែវិច្ឆិកា ឆ្នាំ២០១៦។
- បានរៀបចំ និងសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីគ្រូបង្គោលស្តីពីគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ ចាប់ពីថ្ងៃទី០៦-០៨ ខែកក្កដា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ក្នុងគោលបំណងឱ្យសិក្ខាកាមក្លាយជាគ្រូបង្គោល និងយកចំណេះដឹងទាំងនេះទៅអនុវត្តនៅក្នុងការងារប្រចាំថ្ងៃ និងបណ្តុះបណ្តាលបន្តដល់អ្នកពាក់ព័ន្ធដែលធ្វើការងារជាមួយកុមារ និងអង្គភាពរបស់ខ្លួន ដែលមានអ្នកចូលរួមចំនួន២៣នាក់ (ស្រី១៣នាក់)។
- បានចូលរួមសហការ សម្របសម្រួល និងសង្កេតការណ៍វគ្គបណ្តុះបណ្តាលស្តីពីការចូលរួមរបស់កុមារ ដែលរៀបចំដោយអង្គការសម្ព័ន្ធចាប់ដៃចំនួន០៤លើក ដែលមានអ្នកចូលរួម៧២នាក់ ក្នុងគោលបំណងកសាងសមត្ថភាព មន្រ្តីអង្គការសង្គមស៊ីវិល ឱ្យយល់ដឹងពីសិទ្ធិចូលរួមរបស់កុមារ និងយកចំណេះដឹងទៅអនុវត្តក្នុងអង្គការ និងក្នុងជីវភាពប្រចាំថ្ងៃរបស់ខ្លួន ព្រមទាំងពង្រឹងសមត្ថភាពគ្រូបង្គោលឱ្យមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលបន្ត ពាក់ព័ន្ធនឹងការចូលរួមរបស់កុមារ។
- បានសហការជាមួយអង្គការយូនីសេហ្វរៀបចំកិច្ចប្រជុំស្តីពីអំពើកេងប្រវ័ញ្ចផ្លូវភេទ និងអំពើរំលោភបំពានកុមារប្រព័ន្ធអ៊ីធើណិត នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួន៧២នាក់(ស្រី១៧នាក់)។ កិច្ចប្រជុំនេះមានគោលបំណង ១-លើកកម្ពស់ការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធអំពីការប្តេជ្ញាចិត្ត ដែលបានធ្វើឡើងនៅក្នុងសេចក្តីថ្លែងការណ៍អំពីចំណាត់ការនៅទីក្រុងឡុងដ៍និងអាប៊ូដាប៊ី ២-កំណត់អត្តសញ្ញាណ និងការការពារជនរងគ្រោះ ៣-លុបបំបាត់សម្ភារៈរំលោភបំពានផ្លូវភេទកុមារចេញពីអ៊ីនធើណិត ៤-ពង្រឹងកិច្ចសហប្រតិបត្តិការទូទាំងសកលលោកដើម្បីតាមប្រម៉ាញ់ជនល្មើស និង៥-កសាងសមត្ថភាពដើម្បីដោះស្រាយអំពើកេងប្រវ័ញ្ចន៍ផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធើណិត។
- បានសហការជាមួយអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីសកម្មភាពសម្រួលសម្រួលរបស់ស្ត្រី កុមារ និងយុវជនក្នុងការតស៊ូមតិ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦ ដែលមានអ្នកចូលរួមចំនួន៨៦នាក់(ស្រី២៦នាក់)។ សិក្ខាសាលាមានគោលបំណង ១-លើក កម្ពស់យល់ដឹងពីការការពារកុមារក្នុងប្រទេស និងក្នុងតំបន់អាស៊ាន។ ២-ចែករំលែកចំណេះដឹងការការពារកុមារក្នុងតំបន់អាស៊ាន។ សិក្ខាសាលានេះ បានទទួលការឧបត្ថម្ភពីអង្គការដែនដីមនុស្សប្រទេសអាឡឺមង់ និងអង្គការ BMZ។ ជាលទ្ធផល ស្ត្រី កុមារ និងយុវជន បានទទួលការយល់ដឹងពីការការពារកុមារក្នុងប្រទេស និងក្នុងតំបន់អាស៊ាន។
- បានសហការជាមួយអង្គការគាំពារកុមារដែលងាយទទួលរងគ្រោះ (VCAO) រៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីបណ្តាញយុវជនក្នុងការលើកកម្ពស់ការតស៊ូមតិកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ នៅខេត្តតាកែវ ដែលមានអ្នកចូលរួមចំនួន៨៩នាក់ (ស្រី៤៦នាក់)។ សិក្ខាសាលាមានគោលបំណងដើម្បី ១-ឱ្យអ្នកពាក់ព័ន្ធ (កុមារ យុវជន និងមនុស្សវ័យក្មេង) អាចសមាហរណកម្មទៅក្នុងក្រុមការងារថ្នាក់ជាតិ និងក្រោមជាតិ ដើម្បីចែករំលែកនូវការអនុវត្តល្អពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងការអនុវត្តសិទ្ធិកុមារចំពោះអ្នកជុំវិញខ្លួន។ ២-ចែករំលែកនូវការអនុវត្តល្អៗ

របស់កុមារ និងយុវជន ព្រមទាំងសម្របសម្រួលពង្រឹងយន្តការតស៊ូមតិពាក់ព័ន្ធនឹងសិទ្ធិកុមារ។ សិក្ខាសាលានេះ បានទទួលការឧបត្ថម្ភពីអង្គការដៃនដីមនុស្សប្រទេសអាឡឺម៉ង់ និងអង្គការ BMZ។ ជាលទ្ធផល អ្នកចូលរួមបានទទួលការយល់ដឹងពីការការពារកុមារក្នុងប្រទេស និងក្នុងតំបន់អាស៊ាន។

៤៩- ក្រសួង ស.អ.យ បានរៀបចំបណ្តុះបណ្តាលស្តីពីនីតិវិធីអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ និងប្រវត្តិការងារនៃការកសាងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបំពេញទម្រង់ និងសំណុំឯកសារពាក់ព័ន្ធសុំកូនអន្តរប្រទេស។ បានធ្វើទស្សនកិច្ចសិក្សានៅប្រទេសវៀតណាម ដើម្បីដកបទពិសោធន៍ និងស្វែងយល់ការងារសុំកូននៅប្រទេសវៀតណាម។

៥០-គ.ជ.ប.ជ បានធ្វើការផ្សព្វផ្សាយអប់រំ បំផុសការយល់ដឹងតាមគ្រប់រូបភាព តាមរយៈវេទិកាសាធារណៈ កិច្ចប្រជុំ សិក្ខាសាលា តាមប្រព័ន្ធអប់រំផ្សព្វផ្សាយនានា រួមទាំងវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្តាញសង្គមយ៉ាងទូលំទូលាយនៅគ្រប់ទីកន្លែងដល់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ ក្រោមជាតិ សាលារៀន និងប្រជាពលរដ្ឋតាមបណ្តាឃុំ សង្កាត់ ភូមិ និងសហគមន៍នានាបានចំនួន៣០,១៩៩លើក មានអ្នកចូលរួមចំនួន៣,៧៤០,២១១នាក់ (ស្រីចំនួន១,៦៧៨,២៣០នាក់) ស្មើនឹង១១,៧៧%។ គ.ជ.ប.ជ បានបង្កើតព័ត៌មានតាមរយៈប្រព័ន្ធអេឡិកត្រូនិក ដូចជា៖ ប្រព័ន្ធអ៊ីមែល (Email), ទ្វីតធ័រ (Twitter), ហ្វេសប៊ុក(Facebook), តេលេក្រាម(Telegram), មេសិនជ័រ(Messenger) និងទូរស័ព្ទ ដើម្បីធ្វើការផ្សព្វផ្សាយអំពីសកម្មភាពរបស់ គ.ជ.ប.ជ ជាសាធារណៈ រហូតដល់អន្តរជាតិ ដើម្បីធានានូវភាពងាយស្រួល និងទាន់ពេលវេលា។

៥១-ក្រសួង អ.យ.ក បានផ្សព្វផ្សាយលេខទូរស័ព្ទជាប្រព័ន្ធព័ត៌មានទាន់ហេតុការណ៍របស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ និងអង្គការLSCW, LICADO, CWCC, និងWEC នៅក្នុងបណ្ណាល័យរោងចក្រ។ ក្រសួងមានកម្មវិធីអប់រំសីលធម៌ ជៀសវាងអំពើហិង្សា ការរើសអើង ដោយសហការជាមួយអង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ ផ្តល់កង់៨៩គ្រឿង សម្ភារៈសិក្សាដល់សិស្សក្រីក្រ៣១៥នាក់ នៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ បានសហការជាមួយអង្គការទស្សនៈពិភពលោក ធ្វើកម្មវិធីទប់ស្កាត់ការជួញដូរពលកម្មកុមារ ផ្តល់ជាមធ្យោបាយធ្វើដំណើរ ឯកសណ្ឋានសិស្ស បានទទួលការបណ្តុះបណ្តាលជំនាញងាយៗនៅតាមមណ្ឌលសិក្សា សហគមន៍ ដើម្បីកាត់បន្ថយ ចំណាកស្រុករបស់ស្ត្រី និងជនពេញវ័យ បំប៉ននាយកសាលាពីវិធានការកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សក្នុងខេត្តគោលដៅ គឺខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពង់ចាម ត្បូងឃ្មុំ និងខេត្តសៀមរាប បានចំនួន៧៨នាក់ ស្រី០៨នាក់។

៥២-ក្រសួងទេសចរណ៍ បានធ្វើការប្រជុំផ្សព្វផ្សាយដល់ម្ចាស់ និងបុគ្គលិកសណ្ឋាគារទូទាំង២៥រាជធានី ខេត្ត អំពីសុវត្ថិភាពទេសចរណ៍បាន៥២៤លើក មានអ្នកចូលរួម២៧៣៥នាក់ ស្រី២.១០៣នាក់។ សរុបការប្រជុំផ្សព្វផ្សាយទាំងអស់បានចំនួន៣.៩៧១លើក មានអ្នកចូលរួមសរុប២៥៣.០៩៤នាក់ ស្រី១៣៣.៩១៤នាក់។

៥៣-ក្រសួងកិច្ចការនារី បានដាក់បញ្ចូលខ្លឹមសារស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព និងកលល្បិចជនល្មើស ទៅក្នុងការអប់រំផ្សព្វផ្សាយ និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបាន

ចំនួន២៧.១៩០លើក មានមនុស្សចូលរួមសរុបចំនួន៣.៥៨៦.៨៧០នាក់ ស្រីចំនួន១.៥៩៩.៩៣៣ នាក់។[២៣]

ទន្ទឹមនោះដែរ ក្រសួងក៏បានផ្សព្វផ្សាយកម្មវិធីអប់រំតាមរយៈវេទិកា វិទ្យុ និងការចុះទៅមូលដ្ឋាន ក្រោមប្រធានបទ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ វិធីសាស្ត្រគ្រប់គ្រង កំហឹង និងកត្តាធ្វើឱ្យគ្រួសារមានសុភមង្គល ដើម្បីបង្កើនការយល់ដឹងជាសាធារណៈដល់សិស្ស និស្សិត យុវជន និងសហគមន៍ ក្នុងការផ្លាស់ប្តូរឥរិយាបថ និងផ្តត់គំនិតរួមគ្នាបញ្ឈប់អំពើហិង្សាគ្រប់ទម្រង់ក្នុងសង្គម ដែលមានអ្នកចូលរួមប្រមាណ១.៣៨២នាក់ (ស្រី៦៧២នាក់)។

ថ្មីៗនេះ ការជួលពរពោះជំនួស តម្រូវឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋានក្នុងការទប់ស្កាត់។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យបង្កើតក្រុមការងារអន្តរក្រសួង ដឹកនាំដោយក្រសួងកិច្ចការនារី ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួស។[២៤]

៥៤-ក្រសួងព័ត៌មានបានធ្វើការផ្សព្វផ្សាយពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមារនៅកម្ពុជាតាមរយៈអង្គភាពផ្សព្វផ្សាយរបស់ជាតិ រួមមានវិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយទំនើប ទស្សនាវដ្តី។ល។ ទាំងនៅថ្នាក់ជាតិ ក្រោមជាតិ និងបានផ្សាយកម្មវិធីមហោស្រពតន្ត្រី និងចម្រៀងកុមារឆ្នាំ២០១៦ (កម្រិតថ្នាក់បឋម) មានបទចម្រៀងស្តីពីអាហារូបត្ថម្ភចំនួន១៥កម្មវិធី, សំណួរចម្លើយ និងល្បែងល្បងប្រាជ្ញា សម្រាប់កុមារថ្នាក់មត្តេយ្យចំនួន២០កម្មវិធី, ចម្រៀងកុមារប្រចាំសប្តាហ៍ដែលមានអត្ថន័យអប់រំ ជាច្រើនចំនួន៥៨កម្មវិធី, រឿងអប់រំខ្លី "ដំបូលត្រជាក់" អត្ថន័យបំបាត់អំពើហឹង្សាក្នុងគ្រួសារចំនួន២កម្មវិធី, រឿងអប់រំខ្លីស្តីពីការយល់ដឹងពីទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៦ ចំនួន២កម្មវិធី និងកម្មវិធីពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន០២កម្មវិធី។[២៥]

៥៥-ក្រសួងបរិស្ថាន បានរៀបចំវគ្គផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូចដល់ថ្នាក់ក្រោមជាតិ និងបានផ្សព្វផ្សាយដល់កុមារ មាតាបិតា ទស្សនកិច្ចសិក្សាស្វែងយល់ពីកុមារ និងបរិស្ថាន រួមទាំងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។[២៦]

៥៦-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយមានកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋាន ក.ជ.ក បានចុះផ្សព្វផ្សាយនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មទាំង២៥ រាជធានី ខេត្ត អំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។[២៧]

**អនុសាសន៍ទី៩ របស់រាជរដ្ឋាភិបាល ឆ្នាំ២០១៥៖**

*ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិក្នុងតំបន់ និងអន្តរជាតិ ដើម្បីរួមគ្នាដោះស្រាយរាល់បញ្ហានានារបស់កុមារ។*

---

[២៣] របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ របស់ គ.ជ.ប.ជ។

[២៤] ប្រភព៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

[២៥] ប្រភព៖ ក្រសួងព័ត៌មាន។

[២៦] ប្រភព៖ ក្រសួងបរិស្ថាន។

[២៧] ប្រភព៖ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ឆ្លើយតបទៅនឹងអនុសាសន៍ខាងលើ ក៏ដូចជាផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ យុទ្ធសាស្ត្រទី៤ "ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយ" សម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

**៥៧**-ក្រសួងមហាផ្ទៃបានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនក្នុងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាក់ទងទៅនឹងកិច្ចគាំពារ និងអភិវឌ្ឍន៍កុមារតូច ជាពិសេសជាមួយគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា ដោយផ្តោតលើកម្មវិធីចុះបញ្ជីកំណើត កម្មវិធីទប់ស្កាត់អំពើហិង្សា កម្មវិធីសេវាសង្គមនៅមូលដ្ឋាន។

ចំពោះយន្តការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ មានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) ដែលជាអ្នកសម្របសម្រួល និងអនុវត្តយ៉ាងពេញលេញនៅសហគមន៍មូលដ្ឋាន ពាក់ព័ន្ធនឹងការងារសេវាសង្គមដែលផ្តោតការយកចិត្តទុកដាក់លើការងារអប់រំមាតា បិតា និងអាណាព្យាបាលកុមារអំពីសុខភាព អនាម័យ អាហារូបត្ថម្ភ ការចិញ្ចឹមបីបាច់ថែរក្សា ការការពារកុមារ និងការចូលរៀនក្នុងមត្តេយ្យសិក្សាសហគមន៍។ កិច្ចការទាំងនេះ ត្រូវបានដាក់បញ្ចូល ទៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទៀតផង។ ឆ្លងតាមកិច្ចការគាំពារ និងអភិវឌ្ឍន៍កុមារតូច ពិតជាមានសារៈសំខាន់ក្នុងការទទួលបាននូវធនធានមនុស្សជំនាន់ថ្មី តាមរយៈការទទួលខុសត្រូវខ្ពស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមាន គ.ក.ស.ក និង គ.ក.ន.ក ជាអ្នកសម្របសម្រួលធ្វើយ៉ាងណាឱ្យកុមារទទួលបាននូវសិទ្ធិជាមូលដ្ឋានទាំង៤របស់ខ្លួនយ៉ាងពិតប្រាកដ និងទទួលបាននូវសេវាទាំងឡាយស្របតាមក្របខណ្ឌគតិយុត្ត និងកម្មវិធីជាតិរបស់រាជរដ្ឋាភិបាល។[២៨]

**៥៨**-ក្នុងនាមសមាជិកអាស៊ាន នៃគណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) រាជរដ្ឋាភិបាល បានចូលរួមយ៉ាងសកម្មរាល់ការងារសកម្មភាពថ្នាក់តំបន់ និងអាស៊ាន។ ក្នុងឆ្នាំកន្លងទៅនេះ គណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ សម្រេចបានលទ្ធផលសំខាន់ដូចខាងក្រោម៖

- បានរៀបចំផែនការបន្តរបស់ ACWC ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ រយៈពេល ៥ឆ្នាំ (២០១៦-២០២០) ជាមួយនិងការអនុវត្តផែនការ Blueprint លើវិស័យវប្បធម៌ និងសង្គមកិច្ចក្នុងសហគមន៍អាស៊ាន ឆ្នាំ២០២៥ ពិសេសធានាភាពស៊ីសង្វាក់គ្នាជាមួយយុទ្ធសាស្ត្រជាក់លាក់នៃផែនការBlueprint។ ដោយឡែកកម្ពុជា នឹងបន្តគម្រោងស្តីពីផលប៉ះពាល់ដោយសារការបម្រែបម្រួលអាកាសធាតុលើស្ត្រី និងកុមារនៅតំបន់អាស៊ាន ដោយផលិតវីដេអូរអប់រំស្តីពី *"យុទ្ធនាការផ្សព្វផ្សាយស្តីពីការកាត់បន្ថយផលប៉ះពាល់ដោយសារការបម្រែបម្រួលអាកាសធាតុលើស្ត្រីនិងកុមារនៅតំបន់អាស៊ាន"*។ វីដេអូរស្តតអប់រំនេះ នឹងត្រូវចែកឲ្យទៅប្រទេសជាសមាជិកយកទៅចម្លងតាម និងបញ្ចូលភាសាទៅតាមបរិបទនៃប្រទេសនីមួយៗ។ គម្រោងនេះនឹងត្រូវអនុវត្តនៅឆ្នាំ២០១៩ខាងមុខ។ ឯកសារទស្សនៈទាននៃគម្រោង នឹងត្រូវដាក់ជូនពិនិត្យនៅកិច្ចប្រជុំលើកទី១៥ ខែតុលា ខាងមុខ។

---

[២៨] ប្រភព៖ ក្រសួងមហាផ្ទៃ។

- បានអនុម័តផែនការសកម្មភាពថ្នាក់តំបន់ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ រយៈពេល១០ឆ្នាំ (២០១៦-២០២៥)។ ផែនការនេះមានគោលបំណងពង្រឹងស្ថាប័នគោលនយោបាយ និងគាំទ្រដល់សសរស្តម្ភផែនការអាស៊ានគ្រប់វិស័យ និងឱ្យសមាជិកអាស៊ាននីមួយៗ មានកិច្ចការពារទប់ស្កាត់ និងផ្តល់សេវាកម្មឱ្យបានគ្រប់ពេញលេញទាំងក្របខណ្ឌច្បាប់ និងយន្តការនានា ក្នុងការលុបបំបាត់អំពើហិង្សាលើស្ត្រី និងកុមារ។
- បានចូលរួមការសិក្សាស្រាវជ្រាវស្តីពីប្រព័ន្ធការពារកុមារនៅតំបន់អាស៊ានដែលដឹកនាំដោយប្រទេសឥណ្ឌូនេស៊ី។
- បានចូលរួមការសិក្សាស្រាវជ្រាវស្តីពីការចូលរួមរបស់កុមារនៅតំបន់អាស៊ាន ឆ្លើយតបទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា១២ និងអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ដែលដឹកនាំដោយប្រទេសហ្វីលីពីន។
- បានបញ្ជូនកុមារចំនួន ០៥រូប និងគណៈប្រតិភូកម្ពុជាចូលរួមវេទិកាកុមារអាស៊ានលើកទី៤ ស្តីពី *"អាស៊ានតែមួយ ទស្សនៈតែមួយដើម្បីកុមារ"* កាលពីថ្ងៃទី២០-២៣ ខែមិថុនា ឆ្នាំ២០១៦ នៅទីក្រុងហាណូយ ប្រទេសវៀតណាម។ ក្នុងវេទិកាកុមារអាស៊ាន បានលើកយកបញ្ហា៤ជាអាទិភាពគឺៈ ១).អំពើជួញដូរ និងការរំលោភបំពានផ្លូវភេទលើកុមារ ២).ការការពារកុមារតាមប្រព័ន្ធអនឡាញ ៣).អំពើហឹហ្សាលើកុមារ និង ៤).ការបម្រែបម្រួល អាកាសធាតុ។
- គណៈប្រតិភូកម្ពុជាបានចូលរួមការវាយតម្លៃគម្រោងស្តីពីសិទ្ធិផ្តល់សញ្ជាតិដល់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន ដែលដឹកនាំដោយប្រទេសវៀតណាម។
- ជាមួយគ្នាផងដែរ ក្នុងនាមសមាជិកអាស៊ាន នៃគណៈកម្មាធិការអាស៊ានស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ (ACWC) បានចូលកិច្ចប្រជុំជាប្រចាំរបស់គណៈកម្មាធិការ កិច្ចប្រជុំពិសេស និងកិច្ចប្រជុំនានាដែលពាក់ព័ន្ធនឹងបញ្ហាកុមារក្នុងតំបន់អាស៊ាន។

៥៩-រាជរដ្ឋាភិបាលកម្ពុជា បានចុះកិច្ចព្រមព្រៀងជាមួយនឹងសាធារណៈរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦។

## ៤- សិទ្ធិចូលរួម[២៩]

ឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ យុទ្ធសាស្ត្រទី៣ "ពង្រឹងការការពារកុមារ និងការបង្ការទប់ស្កាត់" សម្រេចបាននូវលទ្ធផលដូចខាងក្រោមៈ

៦០-រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានយកចិត្តទុកដាក់ពង្រីកសិទ្ធិចូលរួមរបស់កុមារ។ តំណាងកុមារបានចូលរួមក្នុងសកម្មភាពសង្គម កិច្ចប្រជុំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្នាក់តំបន់ និងអន្តរជាតិជាច្រើន។ រាល់ការចូលរួមរបស់កុមារ គ្រប់មតិយោបល់ និងសំណូមពររបស់កុមារត្រូវបានយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍសិទ្ធិកុមារ។ ខាងក្រោមនេះ គឺជាលទ្ធផលសំខាន់ៗស្តីពីការចូលរួមរបស់កុមារៈ

- កុមារចំនួន០៥នាក់ ស្រី០៣នាក់ បានចូលរួមវេទិកាកុមារអាស៊ានលើកទី៤ ក្រោមប្រធានបទ" អាស៊ាន១ ទស្សនៈ១ សម្រាប់កុមារ" នៅប្រទេសវៀតណាម នៅថ្ងៃទី២០-២៣ ខែមិថុនា ឆ្នាំ

[២៩] សិទ្ធិនេះគ្របដណ្តប់លើសិទ្ធិរបស់កុមារក្នុងការចូលរួមបញ្ចេញមតិរបស់ខ្លួនគ្រប់បញ្ហា និងត្រូវបានគេទទួលស្តាប់ក្នុងគ្រប់សេចក្តីសម្រេចដែលប៉ះពាល់ដល់អាយុជីវិតរបស់កុមារ។ នៅពេលសមត្ថភាពរបស់កុមារវិវត្តឡើង កុមារគួរតែមានឱកាសកាន់តែច្រើនជាងមុន ក្នុងការចូលរួមសកម្មភាពរបស់សង្គម ដើម្បីជាការរៀបចំសម្រាប់ជីវិតជាមនុស្សពេញវ័យ។

២០១៦ ក្រោមការសម្របសម្រួលដោយអគ្គលេខាធិការដ្ឋាន ក.ជ.ក។ វេទិកានេះមានគោលបំណងកសាងសហគមន៍អាស៊ានមានលក្ខណៈកុមារមេត្រី និងលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ។

- អគ្គលេខាធិការដ្ឋាន ក.ជ.ក បានសម្របសម្រួល និងសហការជាមួយវិទ្យាស្ថានសិល្បៈភ្នំពេញអន្តរជាតិក្នុងការរៀបចំការប្រឡងគូរគំនូរសម្រាប់កុមារក្រោមប្រធានបទ **"រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន"** ក្នុងគោលបំណងឱ្យកុមារបានចូលរួមបង្ហាញសមត្ថភាពចំណេះដឹងពាក់ព័ន្ធនឹងអំពើហិង្សា និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន និងដើម្បីចូលរួមអបអរសាទរទិវាកុមារអន្តរជាតិ១មិថុនា ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៦ ដែលមានកុមារចូលរួមចំនួន២២០នាក់។
- ក្រុមប្រឹក្សាកុមារមាន៧.៩៣១ក្រុម ៣៩.៥៧៨សាខា ២៣១.៩០៨អនុសាខា និងសមាជិក១.៤៧១.៥៤២នាក់។ ក្រុមប្រឹក្សាយុវជនមាន៩៥១ក្រុម ៦.០៨២សាខា ៣៦.៥៦៩អនុសាខា និងសមាជិក២៩៦.៣៦២នាក់។[៣០]
- ក្រសួងអប់រំ យុវជន និងកីឡា បានបោះជំរំយុវជនក្រោមប្រធានបទ "យុវជន និងវិទ្យាសាស្ត្រ" ដោយសហការជាមួយអង្គការដៃគូ មានអ្នកចូលរួម១៣១នាក់ ស្រី៣៩,៧%។ បានបោះជំរុំអន្តរជាតិ ដោយមានសិស្ស និស្សិតចូលរួម១,៨០០នាក់ ស្រី៥៥,៥៥%។[៣១]
- ក្លឹប/ក្រុមកុមារមានចំនួន៥៣៧ ដែលមានកុមារចំនួន៨.៩២២នាក់ នៅតាមសាលារៀន និងសហគមន៍ ដឹកនាំដោយកុមារ និងយុវជននៃអង្គការមិនមែនរដ្ឋាភិបាល។[៣២]
- យុវជនកាកបាទក្រហមកម្ពុជាសរុបចំនួន២១.៧១០នាក់ (ស្រី១៣.១៧៣នាក់) ទីប្រឹក្សាយុវជនកាកបាទក្រហមកម្ពុជាចំនួន១.០៥៨នាក់ (ស្រី២៥១នាក់) នៅគ្រឹះស្ថានសិក្សាចំនួន៤៥៦ នៅ២៣រាជធានី ខេត្ត។ អ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជាទាំង២៣រាជធានី ខេត្តមានចំនួនសរុប១២.១៥៥នាក់ (ស្រី៤.៨៣០នាក់) ដែលបានទទួលការបណ្តុះបណ្តាលការយល់ដឹងអំពីចលនា គោលការណ៍គ្រឹះ និងច្បាប់មនុស្សធម៌អន្តរជាតិ វិជ្ជាសង្គ្រោះបឋម និងជំនាញការងារ ជាក់លាក់ពាក់ព័ន្ធនឹងការអប់រំសុខភាពស្ត្រី ទារកនិងកុមារ ទឹកស្អាត និងអនាម័យ ផ្សព្វផ្សាយ អំពីគ្រោះថ្នាក់ដោយសារមីន គ្រោះថ្នាក់ចរាចរណ៍ និងការគ្រប់គ្រងគ្រោះមហន្តរាយ។ល។[៣៣]
- កុមារ និងយុវជន បានចូលរួមខួបលើកទី៦៧ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៥ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ក្រោមប្រធានបទ **"រួមគ្នាការពារកុមារពីអំពើហិង្សា និងការប្រើប្រាស់គ្រឿងញៀន"** និង **"រួមគ្នាបញ្ចប់ពលកម្មកុមារនៅក្នុងចង្វាក់ផលិតកម្ម"**។

## III-បញ្ហាប្រឈម

---

[៣០] របាយការណ៍បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៥-២០១៦ និងទិសដៅឆ្នាំសិក្សា២០១៦-២០១៧។

[៣១] របាយការណ៍បូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៤-២០១៥ និងទិសដៅឆ្នាំសិក្សា២០១៥-២០១៦។

[៣២] របាយការណ៍ស្តីពីការចូលរួមរបស់កុមាររបស់ NGOCRC និង CCYMCR។

[៣៣] របាយការណ៍សកម្មភាពការងារឆ្នាំ២០១៦ និងផែនការសកម្មភាពការងារឆ្នាំ២០១៧ របស់កាកបាទក្រហមកម្ពុជា។

៦១-ទោះបីគោលនយោបាយ និងកម្មវិធីជាតិ ជាពិសេសផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ បាននិងកំពុងអនុវត្តល្អគួរឲ្យកត់សម្គាល់ក៏ដោយ ក៏ស្ថានភាពកុមារនៅមានភាពប្រឈមនៅឡើយ ដូចជា៖ ប្រព័ន្ធគាំពារសង្គម សុខភាព ការអប់រំ ជាពិសេសនៅតាមតំបន់ជនបទ ។ល។ ប្រជាជនយើងភាគច្រើនជាកសិករ កូនៗរួមទាំងកុមារនៅក្នុងបន្ទុកគ្រួសារត្រូវចូលរួមការងារស្រែចម្ការជាមួយឪពុកម្តាយរបស់ពួកគេតាំងពីដើមរៀងមកដើម្បីជីវភាព។ គ្រួសារមួយចំនួនទៀត បានចំណាកស្រុក ដែលនាំឱ្យប៉ះពាល់ដល់កុមារ ជាពិសេសការរៀនសូត្រ សុខភាពជាដើម។ លើសពីនេះទៀត ផលប៉ះពាល់ចំពោះកុមារដែលមាននាពេលបច្ចុប្បន្ន គឺការប្រើប្រាស់គ្រឿងញៀនដែលបាននិងកំពុងរីករាលដាល ពីទីក្រុងទៅជនបទ។ល។

៦២-ការអនុវត្តច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធស្តីពីការការពារកុមារ ការកាត់បន្ថយ និងការលុបបំបាត់ពលកម្មកុមារ កុមារប្រើប្រាស់សារធាតុញៀន អំពើជួញដូរកុមារ អំពើហិង្សា ការកេងប្រវ័ញ្ចគ្រប់រូបភាព ការសុំកូនអន្តរប្រទេស។ល។ និងធានាការពារកុមារឱ្យរីកលូតលាស់មានសុខុមាលភាពកុមារ មិនទាន់បានផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅឡើយ ពិសេសការអនុវត្តរាល់លិខិតបទដ្ឋានទាំងនេះនៅមានកម្រិតនៅឡើយ។

៦៣-ការចូលរួមរបស់កុមារពិសេស នៅតាមសហគមន៍នៅមិនទាន់បានទូលំទូលាយនៅឡើយ ដោយអាជ្ញាធរមូលដ្ឋានមួយចំនួន មិនទាន់បានផ្តល់ឱកាសឲ្យកុមារ ក្នុងការបញ្ចេញមតិយោបល់ និងបញ្ហានានារបស់កុមារ ក្នុងការចូលរួមកសាងផែនការ និងកម្មវិធីអភិវឌ្ឍន៍នានាដើម្បីកុមារ។

## IV-ទិសដៅអនុវត្តបន្ត

៦៤-បន្តធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ លិខិតបទដ្ឋាន ផែនការជាតិ យុទ្ធសាស្ត្រជាតិ អនុសញ្ញាស្តីពីសិទ្ធិកុមារនិងពិធីសារបន្ថែម និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ ព្រមទាំងជំរុញការអនុវត្ត ដើម្បីចាត់វិធានការការពារកុមារ កាត់បន្ថយ និងលុបបំបាត់អំពើជួញដូរកុមារ អំពើហិង្សានិងការកេងប្រវ័ញ្ចគ្រប់រូបភាព។

៦៥-ជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨ ក្នុងគោលបំណងបង្កើនកម្លាំងចលករគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធានាសម្រេចបាននូវសូចនាករសំខាន់ៗ ឆ្លើយតបនឹងការលើកកម្ពស់សិទ្ធិកុមារ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណតំណាក់កាលទី៣ នៃរាជរដ្ឋាភិបាលកម្ពុជា។

៦៦-បន្តអន្តរាគមន៍កម្មវិធីសុខភាព ដោយផ្តោតលើការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា តាមរយៈការផ្តល់សេវាគ្រប់ជ្រុងជ្រោយ រួមមានសេវាបង្ការ ពិនិត្យពិគ្រោះ ព្យាបាល និងថែទាំ។

៦៧-បន្តលើកកម្ពស់គុណភាពវិស័យអប់រំ ដោយបង្កើនអត្រាចូលរៀនរបស់កុមារ កាត់បន្ថយអត្រាត្រួតថ្នាក់និងអត្រាបោះបង់ការសិក្សា បង្កើនចំនួនសាលាកុមារមេត្រី សាលារៀនជំនាន់ថ្មី និងបង្កើនការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ព្រមទាំងអនុវត្តកម្មវិធីអប់រំបរិយាប័ន្ន និងការអប់រំពហុភាសាចាប់ពីថ្នាក់មត្តេយ្យសិក្សា។

៦៨-បន្តជំរុញការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ បទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារនៅក្នុងមណ្ឌល និងបទដ្ឋានអប្បបរមាសម្រាប់ថែទាំកុមារនៅតាមសហគមន៍ ដោយពង្រឹងគុណភាពនៃការថែទាំ កុមារនៅតាមមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងជំរុញការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។ បន្តដោះស្រាយបញ្ហាជនអនាថា និងការផ្តល់សេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ចំពោះអនីតិជនដែលប្រព្រឹត្តល្មើសនឹងច្បាប់នៅតាមសហគមន៍ពន្ធនាគារ និងជំរុញការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន។

៦៩-ជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (២០១៦-២០២៥) ដើម្បីទប់ស្កាត់ និងការពារកុមារពីគ្រប់ទម្រង់នៃពលកម្មកុមារ ក្នុងការផ្តល់ឱកាសឱ្យកុមារ និងក្រុមគ្រួសាររបស់ពួកគេទទួលបានការអប់រំ បណ្តុះបណ្តាលជំនាញ និងបង្កើនជីវភាពរស់នៅ។

៧០-ជំរុញការអនុម័តផែនការសកម្មភាពជាតិស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា ដើម្បីឆ្លើយតបនឹងការការពារកុមារពីអំពើហិង្សាគ្រប់រូបភាពឲ្យមានប្រសិទ្ធភាព។

៧១-បន្តការផ្សព្វផ្សាយ អប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរនិងកេងប្រវ័ញ្ចកម្លាំង ពលកម្ម អំពើហិង្សា និងបទល្មើសពាក់ព័ន្ធនានាឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ និងជនងាយរងគ្រោះ ព្រមទាំងបន្តការចុះផ្សព្វផ្សាយដល់អាជីវកម្មទេសចរណ៍ឲ្យយល់អំពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

៧២-បន្តពង្រឹង និងពង្រីកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅគ្រប់ថ្នាក់ ដើម្បីជាយន្តការសម្របសម្រួលជួយដល់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចលើវិស័យការងារកុមារឲ្យមានប្រសិទ្ធភាព។

៧៣-ពង្រីកការចូលរួមរបស់កុមារ តាមរយៈព្រឹត្តិការណ៍ជាតិ ក្រោមជាតិ តំបន់ និងថ្នាក់អន្តរជាតិនានា។ រាល់មតិយោបល់របស់កុមារត្រូវយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានាសម្រាប់អភិវឌ្ឍសិទ្ធិរបស់ពួកគេ។

៧៤-បន្តពង្រីកកិច្ចសហការជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ សហគមន៍ ប្រជាពលរដ្ឋ មាតាបិតា អាណាព្យាបាល សំដៅជំរុញលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ ជាពិសេសបន្តការអនុវត្តសារាចរណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ០៨សរណនចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា និងសារាចរណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ០៤សរ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ពាក់ព័ន្ធនឹងការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា។

## V-សេចក្តីសន្និដ្ឋាន

**៧៥**-រាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់ និងចាត់វិធានការជាច្រើនដើម្បីលើកស្ទួយវិស័យកុមារ។ ជាក់ស្តែងបច្ចុប្បន្នកម្ពុជាបានធ្វើឲ្យស្ថានភាពសិទ្ធិកុមារកាន់តែមានភាពល្អប្រសើរជាលំដាប់ រួមមានការផ្តល់សេវាលើសុខុមាលភាពមាតា ទារក និងកុមារ ការចុះឈ្មោះចូលរៀនមានការកើនឡើង ការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដើម្បីឲ្យកុមារទទួលបានការអប់រំ ការបណ្តុះ

បណ្តាលវិជ្ជាជីវៈ សមាហរណកម្មទៅក្នុងសង្គម ការលើកកម្ពស់ការងារសមរម្យ និងសុវត្ថិភាពកុមារ។ ការរំលោភបំពាន ការជួញដូរកុមារ និងអំពើហិង្សាលើកុមារត្រូវបានទប់ស្កាត់ បង្ក្រាប និងចាត់វិធានការតាមផ្លូវច្បាប់ជាបន្តបន្ទាប់។ ព្រមជាមួយនេះ ដើម្បីពង្រឹងកិច្ចការពារ និងបន្តលើកកម្ពស់ការអនុវត្តសិទ្ធិកុមារ រាជរដ្ឋាភិបាលបានបង្កើតច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព និងយន្តការជាតិជាច្រើន ព្រមទាំងបានធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលយ៉ាងទូលំទូលាយដល់ទូទាំងរាជធានី ខេត្ត។

ក.ជ.ក សូមសម្តែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលតែងបានគិតគូរខ្ពស់ដល់ការអភិវឌ្ឍកុមារក្នុងនោះ ការដឹកនាំ ការស្តារ និងការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យបានផ្សារភ្ជាប់ជាមួយនឹងបុព្វហេតុកុមារ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** តែងផ្តល់នូវសេចក្តីអាណិតស្រឡាញ់ សណ្តោសប្រណីចំពោះកុមារគ្រប់ស្រទាប់ទាំងអស់ តាមរយៈការកសាងសាលារៀនរាប់ពាន់ខ្នង មន្ទីរពេទ្យ មណ្ឌលសុខភាព មណ្ឌលកុមារកំព្រា មណ្ឌលកុមារពិការ និងការជួយឧបត្ថម្ភដល់កុមារកំព្រា កុមារក្រីក្រកុមារពិការជាច្រើន។

ក.ជ.ក សូមកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ចំពោះសកម្មភាពឆ្លើយតបដ៏មានប្រសិទ្ធភាព ក្នុងការជួយដល់ប្រជាជនដែលក្រីក្រងាយរងគ្រោះគ្រប់ទីកន្លែង។

ក.ជ.ក សូមសម្តែងនូវអំណរគុណដល់គ្រប់ក្រសួង ស្ថាប័នជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលនានា ប្រជាជន សហគមន៍ ព្រះសង្ឃ គ្រូអាចារ្យ មាតាបិតា និងកុមារខ្លួនឯងផ្ទាល់ ដែលបានចូលរួមចំណែកក្នុងការអនុវត្តសិទ្ធិកុមារនៅកម្ពុជាឲ្យមានការរីកចម្រើន ស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ។

*រាជធានីភ្នំពេញ, ថ្ងៃទី ខែឧសភា ឆ្នាំ២០១៧*

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**